មជ្ឈមណ្ឌលឯកសារកម្ពុជា

BBI0071

# សម្ភាសន៍ជាមួយឈ្មោះ កៅ សុន ភេទប្រុស អាយុ៥៣ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានអនុសេនាធំ កងពល៦២០

មុខងារបច្ចុប្បន្នៈ កសិករ

ស្រុកកំណើតនៅភូមិខ្ពបតាងួន ឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

សព្វថ្ងៃរស់នៅភូមិស្វាយជ្រុំ ឃុំអូរដារ ស្រុកកំរៀង ខេត្តបាត់ដំបង

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០១:៣០:៤៦

៤៤ ទំព័រ

ដានី : ចឹងជំបូងពូខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះពេញឈ្មោះអីដែរ?

សុន : ឈ្មោះ កៅ សុន ។

ដានី : ពូអាយុប៉ុន្មានហើយ?

សុន : អាយុ៥៣ ។

ដានី : ៥៣ឆ្នាំ?

សុន : បាទ!

ដានី : សព្វថ្ងៃពូ ភូមិនេះគេហៅភូមិអីដែរ សព្វថ្ងៃ?

សុន : ស្វាយជ្រុំ ។

ដានី : ពូរស់នៅក្នុងភូមិស្វាយជ្រុំ?

សុន : បាទ! ស្វាយជ្រុំ ។

ដានី : ស្វាយជ្រុំ ឃុំអីដែរ?

សុន : អូរដារ ស្រុកកំរៀង ខេត្តបាត់ដំបង ។

ដានី : ស្រុកកំណើតពូ នៅណាភូមិអី ឃុំអី?

សុន : បាទ! នៅខ្ពបតាងួន ភូមិខ្ពបតាងួន ស្ទឹងត្រង់ កំពង់ចាម ។

ដានី : ភូមិខ្ពបតាងួន ឃុំខ្ពបតាងួនដែរ ។ មីងគាត់ឈ្មោះអីដែរ គ្រួសារពូ?

សុន : ប្រាក់ និត ។

ដានី : គាត់អាយុប៉ុន្មានដែរ?

សុន ៖ អាយុ៥០ប៉ុន្មាន ៥៣ នឹងហើយបងខ្ញុំម៉ាឆ្នាំ ៥៤ ។

ដានី ៖ មីងគាត់អ្នកស្រុកណាដែរ?

សុន ៖ បាភយណ៍ ។

ដានី ៖ អ្នកបាភយណ៍ មីងនៅភូមិណាដែរ?

សុន ៖ នៅបាភយណ៍ហ្នឹងទាំងអស់ ។

ដានី ៖ ភូមិបាភយណ៍?

សុន ៖ ស្រុកក៏បាភយណ៍ ។

ដានី ៖ ភូមិបាភយណ៍ ឃុំបាភយណ៍ ស្រុកបាភយណ៍ទៀត នៅកំពង់ធំ ជិតកំពង់ចាមដែរ បាភយណ៍ ខាងជើងព្រៃ ជិតស្គន់?

សុន ៖ បាទ! ទៅឆ្ងាយដែរ ស្គន់ ។

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់ដែរ?

សុន ៖ ខ្ញុំកូនតែ៣ ស្រី១ ប្រុស២ ។

ដានី ៖ ស្រី១ ប្រុស២ ។ ធំៗអស់ហើយ?

សុន ៖ ធំៗអស់ហើយ នៅរៀនមួយ មួយរៀនជាប់បាក់ឌុបហើយ ។

ដានី ៖ រៀនជាប់បាក់ឌុប ទៅរៀនសាលាណាទៀតទេ?

សុន ៖ កំពុងរកសាលាហ្នឹង ថ្ងៃប៉ុន្មានទៅប្រឡងអាហារូបករណ៍ជាប់អស់ កំពុងដាក់ពាក្យនៅវត្តជីវីសនឹង ។ ឲ្យវាប្រឡងទៅចេះជាប់ ។

ដានី ៖ ទៅខាងបាត់ដំបង?

សុន ៖ បាទ!

ដានី ៖ ទើបជាប់ឆ្នាំហ្នឹង?

សុន ៖ ជាប់ បាទ!ជាប់ឆ្នាំទៅ ។

ដានី ៖ ២ទៀតកំពុងតែរៀន?

សុន ៖ មួយទៀតរៀន អាមួយស្រីនោះឈប់ មីស្រីបងឈប់ៗរៀនតាមពីថ្នាក់ទី៧ ។

ដានី ៖ សព្វថ្ងៃពូប្រកបមុខរបររកស៊ីធ្វើអីដែរ?

សុន ៖ ធ្វើចំការ ធ្វើស្រែ ។

ដានី ៖ ធ្វើចំការ ធ្វើស្រែ ។ ចំការធ្វើចំការអីខ្លះទៅ?

សុន ៖ ចំការដំឡូង ពោត សណ្តែក ។

ដានី :	ពោត សណ្តែក ហើយនឹងស្រែដែរ?

សុន :	បាទ! ស្រូវ ។

ដានី :	ពូឪពុកពូឈ្មោះអីដែរ?

សុន :	ឪពុកខ្ញុំឈ្មោះ កៅ សុខ ។

ដានី :	គាត់ខូចហើយ?

សុន :	ខូចនឹង ខូចតាំងពីមើលខ្ទង់៨៧ ។

ដានី :	ឆ្នាំ៨៧ ដោយសារជម្ងឺ?

សុន :	ជម្ងឺគាត់ ។

ដានី :	ចុះម្តាយពូ?

សុន :	ម្តាយនឹង គាត់ខូចមុនឪពុកខ្ញុំ ។

ដានី :	ខូចមុន?

សុន :	ម្តាយខ្ញុំខូចខ្ទង់ឆ្នាំណា ខ្ញុំមិនសូវចាំ ខ្ទង់៧៧ ។

ដានី :	បាទ! ដោយសារអីដែរ?

សុន :	គាត់ឈឺដែរ ជម្ងឺដែរ អស់អីមិនដឹងខ្ញុំអត់ចាំ ប្អូនខ្ញុំបានគាត់ដឹង ។

ដានី :	គាត់ឈ្មោះអីដែរ?

សុន :	ហ៊្វឹង សៀ ឆាន់ សៀ ។

ដានី :	ឆាន សៀ?

សុន :	បាទ!

ដានី :	ពូមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

សុន :	ខ្ញុំនោះ បងប្អូនបង្កើត៦នាក់ ។

ដានី :	បង្កើត៦នាក់?

សុន :	បាទ!

ដានី :	ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សុន :	ស្រី២ ។

ដានី :	ប្រុស៤?

សុន :	បាទ!

ដានី :	ពូកូនទីប៉ុន្មាន?

សុន ៖ ខ្ញុំបងគេ ។

ដានី ៖ កាលពីក្មេងៗពូមានបានរៀនសូត្រអីដែរអត់?

សុន ៖ ខ្ញុំរៀនសាលាវត្ត រៀននៅវត្តលោក រៀនបានតិច ។

ដានី ៖ វត្តនៅវត្ត?

សុន ៖ បាទ! នៅនឹងវត្តហ្នឹង ។

ដានី ៖ វត្តខ្ពបតាឌួនហ្នឹង?

សុន ៖ បាទ!

ដានី ៖ ពូចេះអាន ចេះសរសេរដែរ?

សុន ៖ ចេះអាន ចេះសរសេរបានខ្លះ ។

ដានី ៖ អឺ! រៀនបានប៉ុន្មានបានឈប់?

សុន ៖ ខ្ញុំរៀនបានតិចដែរ ប្រហែលជា៣-៤ឆ្នាំហ្នឹង យើងជំនាន់ហ្នឹងចូលធ្វើទាហានខ្មែរក្រហមចូលទ័ព ។

ដានី ៖ បាទ! ចូលឆ្នាំណា?

សុន ៖ ហ្នឹង៧៣នឹង ។

ដានី ៖ ចឹងរៀនដល់២-៣ឆ្នាំ ដល់ឆ្នាំ៧៣នឹងក៏ចូលទ័ព?

សុន ៖ បាទ! នៅរៀននឹងហើយ៧៣ក៏ចូលធ្វើទ័ព រៀនសូត្រចេះដឹងច្រើន ខ្ញុំរៀនក្នុងព្រៃរៀននឹងខ្មែរក្រហមនឹងទេ របៀបថាយើងធ្វើការផងរៀនផង ។

ដានី ៖ ចុះពូចូលឆ្នាំ៧៣ចូលទ័ពៗខាងណា?

សុន ៖ កាលហ្នឹងគេហៅចល័យភូមិភាគ ។

ដានី ៖ ចល័តភូមិភាគ?

សុន ៖ កាលនឹងភូមិភាគយើងម៉ាដួរនឹងមិន៣០៤ ។

ដានី ៖ បាទ!ចល័ត?

សុន ៖ ភូមិភាគ៣០៤ ។

ដានី ៖ ភូមិភាគ៣០៤ កាលនឹងពូស្ម័គ្រចិត្តចូល ឬក៏?

សុន ៖ កាលនឹងបើនិយាយទៅបើថាជំនាន់នឹង ចូលតាមគ្នាតាមនេះគ្មានអ្នកណានៅម៉ាភូមិៗចូលអស់ស្ម័គ្រចិត្តចូលចឹងម៉ង គ្មានអ្នកណាបង្ខំ ។

ដានី : កាលនឹងយើងដូចថាមានគេមកឃោសនា គេមកប្រាប់ថាចូលកងទ័ពអីយ៉ាងម៉េចៗ យើង ធ្វើដើម្បីអីៗគេមានមក?

សុន : កាលនឹងគេឃោសនចឹងថាយើងចូលទ័ពអីចឹង គេរំដោះជាតិអីចឹង។

ដានី : ខាងណាគេអ្នកមកប្រាប់យើង?

សុន : ខាងខ្មែរក្រហមដូចថាថ្នាក់មន្ទីរស្រុក យោធាស្រុក យោធាតំបន់អីចឹង។ ចុះកាលនឹងគេមិនត្រូវការកម្លាំងទាហានអីចឹងវៃជាមួយអាមេរិច វៃជាមួយលន់ នល់។

ដានី : កាលនឹងចូលគ្នាច្រើនទេ កាលជំនាន់ពូ?

សុន : ភូមិខ្ញុំចូលម៉ាសារនឹងប្រហែល៣០នាក់។

ដានី : ប្រហែល៣០នាក់?

សុន : បាទ! ៣០នាក់ចូល ធ្វើមេទិញ ធ្វើសរុបទូទាំងឃុំម៉ងច្រើនរាប់រយ។

ដានី : ដល់យើងចូល ហើយយើងទៅនៅណាដំបូង?

សុន : ខ្ញុំទៅនៅព្រែកសង្កែ។

ដានី : នៅព្រែកសង្កែ?

សុន : នៅយាមពាម កន្លែងខ្ញុំយាមនៅមាត់ទន្លេពាមនឹងទៅមកៗ មន្ទីរខ្ញុំនៅកន្លែងជើងភ្នំនឹង ព្រែកសង្កែ ខ្ញុំនៅតែព្រែកសង្កែៗនឹង។ ព្រលឹមឡើងហូបបាយហើយទៅយាមនៅពាម គេឲ្យយាមតាមមាត់ទន្លេ កុំឲ្យថ្នាំចេញឆ្លងទៅភូមិភាគ ឆ្លងទៅភូមិភាគ ឆ្លងទៅក្រូចឆ្មារ ក្រូចអី កាលនឹងទំនិញឆ្លងកាត់ភូមិភាគគេអត់ឲ្យចេញទេ ថ្នាំ។ ចាប់អ្នកលក់ថ្នាំលក់អី គេអត់ឲ្យឆ្លងកាត់ទេ ទាល់តែមានច្បាប់មានទម្លាប់អីកាលនឹង គេឲ្យយាមតាមនឹង តាមមាត់ទន្លេ។

ដានី : អ្នកនឹងដូចថាថ្នាមជក់គេចំហ៊ុយបាននេះ គេយកទៅលក់ខាងក្រូចឆ្មារ?

សុន : បាទ! លក់ក្រូចឆ្មារ បានដល់ចឹងកាលនឹងគេអត់ឲ្យចេញទេខាងនេះនោះ ក្រូចឆ្មារមិនកាលនឹងមិនភូមិភាគផ្សេង ក្រូចឆ្មារទៅចូលភូមិភាគ។

ដានី : ៧០៣?

សុន : បាទ! ទៅកាលនឹងខាងបូព៌ាកាលនឹងនោះ។

ដានី : មានចាប់បានទេ?

សុន : ចាប់ប្អូនអើយ ចឹងបានខ្ញុំអត់បេះនៅអាទ័ពនឹង ស្អប់។ ចឹងខ្ញុំអត់បេះនៅ ខ្ញុំសុំគេឡើងមកមុខបណ្ដោយ ឡើងមកទាហានវៃមុខនេះ។ ឡើងមកតំបន់ៗគេបញ្ជូនមកតំបន់អាបិទផ្លូវអី

ខ្ញុំមកនៅក្នុងកូនវិទ្យុ ។ ហើយក៏ខ្ញុំនៅនឹង ដល់នៅនឹងខ្ញុំអត់ចេះនៅទៀត ជិតផ្ទះនឹកផ្ទះ ។ ចឹងខ្ញុំសុំគេឡើងមកទាហានយើង ទាហានកងល័ត ដូចថាកងចល័តភូមិភាគ៣០៤នឹងគេរៀបថ្មី ចឹងគេរៀបចំនេះ ខ្ញុំអត់ត្រូវមានឈ្មោះមកទេ គេហៅតំរង់ជួរគេហៅតែអ្នកចាស់ៗ ។ និយាយទៅខ្ញុំក្មេងជាងគេ បាទ! ខ្ញុំចូលដំបូងអាយុប៉ុន្មានអាយុ១៥-១៦ ។

ដានី : តែ៧/៣ហ្នឹងទេ?

សុន : បាទ! ដល់ពេលនេះទៅ គេជ្រើសរើសនេះនឹង ខ្ញុំរត់ចូលជួរមកខ្ញុំអត់ចេះនៅក្បែរនឹង ម៉្យាងដូចថាយើងនៅក្រោយលំបាក គេលុតដំ ហើយខ្ញុំអត់ចេះហូបបាយលាយចេក ខ្ញុំអត់ នៅទេ ។ បាយអង្ករអីយើងមិនចេះខ្វះទេ ប៉ុនគេឲ្យហូបលាយចឹង ខ្ញុំអត់ចេះហូបៗទៅ ល្ហូរ ។ ចឹងខ្ញុំរត់ចូលជួរចឹង ដល់ទាហានតំបន់គេឲ្យអានេះមួយចាប់មកវិញចឹង មិនបាច់ចាប់ ឲ្យវាទៅ ។ ចឹងខ្ញុំមកម៉ង ខ្ញុំរត់មកនៅជាមួយទ័ពគេនេះ ។ គេរៀបចំអង្គភាពដំបូង ៤វរៈ គេរៀបចំនៅស្រុកបាធាយនៅវត្តបាធាយនឹង ។ បាទ! ខ្ញុំរៀបចល័តភូមិភាគរៀបនៅនឹង ហើយបានទៅវ៉ៃនៅព្រែកក្ដាម នៅ ។

ដានី : ចុះពូកាលចូលដំបូងគេឲ្យមកនៅខាងជើងភ្នំ នៅព្រែកសង្កែ?

សុន : នៅហ្នឹង នៅយាមនៅនឹងប្រហែលជា៣ខែ ។

ដានី : ៣ខែ?

សុន : បាទ! បានឡើងទៅបាញ់លូន ។

ដានី : កាលនឹងយ៉ាងម៉េចយើងចាប់ផ្ដាំគេច្រើន អ្នកស្រុកគេអត់សូវចូលចិត្ត អត់សូវសប្បាយចិត្ត?

សុន : ដល់ចាប់ផ្ដាំចឹង យើងថាខាងទាហានយើង ខាងស្រុកយើងនឹងដូចថានៅព្រែកសង្កែនឹង ទាហានស្រុកតឹងតែងពេកចឹង ។ គាត់ថាទៅគាត់លួចយកលក់ទេ លួចឆ្លងចឹងទៅ គេមិនឲ្យឆ្លង ប៉ុន្តែអានឹងផ្ដាំរបរដែលគាត់ធ្វើបានហើយ គាត់មិនដឹងលក់ទៅណា គាត់មានលក់ទៅចឹង ។ ដល់ចឹងគេមិនឲ្យឆ្លងគាត់លក់នឹង យាត់ៗខ្ញុំអត់ចេះនៅប្រជាជនស្អប់ សូម្បីនៅជើងភ្នំនឹងនេះដែរ គេឲ្យយាម ។

ដានី : ចឹងនៅព្រែកសង្កែនឹងមានស្រុកមួយដែរ សាលាស្រុកមាន?

សុន : បាទ! អាត្រង់នឹងស្រុកតើ ព្រែកសង្កែស្រុកតើ ។

ដានី : គេហៅស្រុកអី?

សុន ៖ អឺ! ជំនាន់នឹងមិនដឹងគេហៅស្រុកអី ប៉ុន្តែត្រង់នឹងទ័ពស្រុក ។

ដានី ៖ ទ័ពស្រុក?

សុន ៖ បាទ!

ដានី ៖ តែមិនដឹងហៅស្រុកអី?

សុន ៖ បាទ! មិនដឹងគេហៅស្រុកអី ។

ដានី ៖ គណៈស្រុកគេឈ្មោះអីគេ?

សុន ៖ គណៈស្រុកគេឈ្មោះ ទៀង ។

ដានី ៖ ឈ្មោះទៀង?

សុន ៖ បាទ! ស្អីទៀងទេ ខ្ញុំអត់ចាំត្រកូលគាត់ទេ ប៉ុនគណៈស្រុកនឹងទៀង ។

ដានី ៖ មានមន្ទីរស្រុកមានអីនៅព្រែកសង្កែ?

សុន ៖ មន្ទីរស្រុកនៅស្រែសង្កែ ខាងជើងភ្នំក៏មានមន្ទីរដែរ កន្លែងឃាមនឹងមានមន្ទីរ ហើយអាមន្ទីរធំកន្លែងបាយកន្លែងទឹកអីស្រែសង្កែ ។

ដានី ៖ ធ្វើស្រែ សង្កែ?

សុន ៖ បាទ! មានស្រីមានប្រុសទាំងអស់ នារីមានកងនារីគេម៉ាកងចឹងទៅខ្លះគេផ្សេងបាយទឹកគេ ផ្សេង ។

ដានី ៖ ខ្ញុំនៅនឹងដែរ ខ្ញុំអត់ដឹងថាមាន ។

សុន ៖ បាទ! មានកាលខ្ញុំនៅ ។ ហើយព្រលឹមឡើងដើរធ្វើការតាមមាត់ទន្លេចឹងរហូត មកដីដុះមកពាមនឹងហែរ ៗ ទៅមក ៗ តាមនឹង ។ ឃាមនឹងមិនឃាមអីទេ ឃាមតែគ្នាឯងអ្នកលួចលក់ថ្នាំលក់អីនឹង ហើយកាណូតឃួនអីវាដឹកអី ៗ ឆ្លងចេះក៏ចាប់ដែរ ជួនណាបាញ់គ្នានៅនឹង បាញ់ញឹក ។

ដានី ៖ បាញ់ជាមួយយួន?

សុន ៖ បាទ! បាញ់ជាមួយយួនជាមួយអីនឹង ។

ដានី ៖ ចឹងនៅបាន៣ខែ ពូឡើងមកខាង?

សុន ៖ ឡើងមកនៅតំបន់ ។

ដានី ៖ ឡើងមកនៅតំបន់ កាលនឹងតំបន់ប៉ុន្មាន?

សុន ៖ តំបន់៣៣ចឹង ខ្ញុំដូចអត់ចាំដែរ ប្រហែល៣៣ ។

ដានី ៖ នៅណា នៅបែកអន្លង់?

សុន ៖ នៅបែកអន្លង់ មន្ទីរនៅអាបែកអន្លង់នៅក្នុងកូនកោះស៊ូតូចៗនឹង មន្ទីរនៅនឹង ប៉ុនដើរធ្វើការ ជិទាន់នឹងធ្វើឆ្ងាយនេះនោះ ទៅស៊ីងជីនិតស៊ីងអី ។

ដានី ៖ កាលជិទាន់នឹងដូចខាងមន្ទីររបស់មជ្ឈឹម ខាងរបស់អង្គការគេនៅម្តុំបិទផ្ទូ បិទអីនឹងដែរ?

សុន ៖ បាទ! នៅម្តុំបិទផ្ទូ ឃ្លាំងកាំភ្លើងនៅអីនោះឆ្លងស៊ីងជីនិតទៅ គេហៅស្ទឹចូលដីកំពង់ធំហើយ នៅម្តុំជិតត្បែងជិតទៅអីនោះ ។

ដានី ៖ អត់ស្គាល់ទេ?

សុន ៖ បាទ! អត់ស្គាល់ ប៉ុនខ្ញុំទៅដល់នឹង ឆ្លងស៊ីងជីនិតទៅទៀត ដើរទៅ ។ ខ្ញុំទៅបើកកាំភ្លើងនៅ ឯហ្នឹង នៅយោធាស្រុកគេឲ្យទៅបើកកាំភ្លើង ឲ្យហាត់ ។

ដានី ៖ ពីណាគេគណៈតំបន់ កាលនឹងគណៈតំបន់?

សុន ៖ គណៈតំបន់ឈុំ មិនដឹងឈ្មោះអីតាឈុំ គេចាប់ជិទាន់នឹងបាត់ ជិទាន់វ៉ៃកំពង់ចាមនឹង គេ ចាប់បាត់ ។

ដានី ៖ ចុះកុយ ធួនកាលនឹងភូមិភាគ?

សុន ៖ ភូមិភាគ កុយ ធួននឹងភូមិភាគទេ ។

ដានី ៖ ភូមិភាគ៣០៤នឹង?

សុន ៖ បាទ!

ដានី ៖ កាលនឹងមានឈ្មោះគាត់ទេ?

សុន ៖ មាន កុយធួននឹងមានហើយ តាឈុំៗខ្ញុំអាចចាំគាត់នឹងអាចគណៈតំបន់ កូនគាត់ពួកម៉ាក់ខ្ញុំ កាលនឹងនៅសិល្បៈ កូនតាឈុំនឹង ។

ដានី ៖ អូ!ចឹង?

សុន ៖ បាទ!

ដានី ៖ កូននៅដែរអត់?

សុន ៖ ឥឡូវមិនដឹងទៅណាទេ វាអត់ចាំ អត់ដែលជួបសោះ តែខ្ញុំចូលនឹងតាមពួកវានឹងដូចថាពួក ម៉ាក់វាមកហាត់សិល្បៈនៅភូមិខ្ញុំយូរៗទៅ វាបបួលទៅ ។

ដានី ៖ មកកូនតាឈុំនឹង?

សុន ៖ បាទ! មកនឹងសិល្បៈនឹងគេដើរលេងគ្រប់តែភូមិ របៀបសិល្បៈឃោសនា គេឃោសនាឲ្យ កម្លាំងគេចូល ។

ដានី ៖ កាលនឹងដូចថាខាងសិល្បៈ៣០៤នឹងលេចធ្លោជាងគេ នៅនេះ?

សុន ៖ បាទ! លេចឆ្ងោ ដើរលេងរហូតដល់ឆ្ងងភូមិភាគទៀត ធ្លាក់ទៅក្រចេះទៅអី ។

ដានី ៖ មានមកដល់ខាងសៀមរាប ខាងបន្ទាយស្រីអី ខ្ញុំឃើញរូបថតកាលពីឆ្នាំ៧២ ៧៣?

សុន ៖ បាទ! ៧២ ៧៣ ។

ដានី ៖ ចុះតាឈុំនឹងគាត់អ្នកស្រុកនៅណាដែរ?

សុន ៖ ខ្ញុំមិនចាំដែរ ប៉ុនគាត់នៅធ្វើការនឹង ប៉ុនមិនដឹងស្រុកគាត់នៅណាខ្ញុំអត់ចាំទេ ។

ដានី ៖ ចុះពូទៅនៅកន្លែងតំបន់រយៈពេលប៉ុន្មាន?

សុន ៖ នៅតំបន់នឹងនៅប្រហែលជា៣ខែដែរនឹង ។

ដានី ៖ បាន៣ខែដែរ?

សុន ៖ ៣ខែដែរបានខ្ញុំទៅទៀត ខ្ញុំមកចាញ់គេខ្ញុំប្រាប់ត្រង់ចាញ់គេបាយលាយចេក អត់ចេះស៊ី ប៉ុនប្រធានក្រុមខ្ញុំគាត់ស្រួលណាស់ គាត់ឲ្យខ្ញុំអត់ឲ្យធ្វើអីទេ ។ គាត់ឲ្យខ្ញុំនៅនឹងផ្ទះនឹងដាំបាយគាត់ប្រាប់ថា «ឯងអត់ចេះស៊ីបាយលាយចេក ឯងដាក់លាយម៉ាចំហៀង ទុកម៉ាចំហៀង ឯងហូបខ្លួនឯងទៅ» ។

ដានី ៖ អូ! គាត់ស្រួលដែរ?

សុន ៖ បាទ! គាត់ស្រួល ។ ហើយគេទៅដឹកប្រឡាយៗអូរទឹកថ្វានឹងប្រឡាយទម្លាក់មកស៊ឹងជីនិត ដី ហើយខ្ញុំអត់ចេះសំខាន់អត់ចេះហូបបាយលាយចេកនឹងហើយ បើថានៅនឹងរត់មកផ្ទះវិញ ។

ដានី ៖ ខ្ញុំឮពូមីងខ្ញុំគាត់និយាយដែរ កាលជំនាន់នឹងគាត់ធ្វើកងចល័ត គាត់ទៅដឹកប្រឡាយអូរទឹកថ្លាដំណើបខ្ទី ។

សុន ៖ បាទ! ប្រឡាយអូរទឹកថ្លាម៉ាតំបន់ដឹកកាត់ព្រៃ ទម្លាក់មកស៊ឹងជីនិត ។

ដានី ៖ ចឹងពូកាលមុនដំបូងទៅនៅកងទ័ពស្រុកទេ ហើយបានមកសុំគេមកនៅតំបន់?

សុន ៖ បាទ!

ដានី ៖ គេឲ្យ?

សុន ៖ គេឲ្យ ខ្ញុំលក្ខខណ្ឌគេចេះ បើថាឲ្យខ្ញុំមកនៅនឹងខ្ញុំរត់ទៅផ្ទះ ។ ហើយជំនាន់នឹងបើតំបន់ រត់ទៅផ្ទះគេតាមចាប់គេវ៉ៃចោល ។ ដល់ចឹងខ្ញុំប្រាប់ ខ្ញុំថា«ខ្ញុំអត់នៅជិតផ្ទះ វរៗខ្ញុំនៅជិតផ្ទះខ្ញុំរត់ទៅនាំតាមខ្ញុំៗខ្លាចគេវ៉ៃចោល មកឲ្យផុតមកបណ្តោយ» មកនៅធ្វើទាហានផុតដល់ចល័តនៅឆ្ងាយចឹងលែងឃើញគ្នាឯងចឹងទៅ យើងលែងនឹក ។

ដានី ៖ ដល់ពេលពូបាននៅតំបន់បាន៣ខែចឹងទៅ ក៏សុំគេចូលមកខាងចល័តភូមិភាគ កងទ័ពចល័តភូមិភាគ?

សុន ៖ បាទ! មកដល់គេរៀបថ្មី មានសៀមរាប មានកំពង់ធំចំរុះ ។

ដានី ៖ ទាំងអស់គ្នា?

សុន ៖ មករៀបនឹងមាន៣វរៈ រៀបចំរុះម៉ងស្រុកណាក៏មានដែរ ។

ដានី ៖ នៅវត្តបាធាយនឹង?

សុន ៖ បាទ! នៅវត្តបាធាយនឹង រៀបនៅបាយនៅវត្តបាធាយ ។

ដានី ៖ បានជាកងពលអីអត់ទេ?

សុន ៖ វរសេនាធំ កាលនឹងអត់ទាន់មានកងពលទេ វរសេនាធំមាន៣វរសេនាធំ ។

ដានី ៖ មាន៣វរសេនាធំ?

សុន ៖ បាទ!

ដានី ៖ ពូនៅវរសេនាធំណាទៅ?

សុន ៖ ខ្ញុំដូចភ្លេចលេខអស់ប្អូននៅកាលនឹង លេខដូច៦៣ចេះមិនដឹង ហើយវរសេនាតូច៤៤៧ចឹង មិនដឹង វារៀបច្រើនដង ។

ដានី ៖ ពីណាគេប្រធានវរៈ?

សុន ៖ ប្រធានវរៈ ដឹបូងវរខ្ញុំមិនដឹបូងឈ្មោះស៊ីនួន ។

ដានី ៖ ស៊ីនួន វរសេនាធំ?

សុន ៖ អឺ! វរៈសេនាតូច គាត់ដឹបូងវរសេនាតូច ក្រោយមករៀបទៀតបានគាត់ឡើងវរសេនាធំ តែស៊ីនួននឹងគាត់ បើនិយាយទៅអ្នកនិស្សិត អ្នកចេះដឹង ដែនទីស្អីៗគាំភ្លើងធំអីគាត់ចេះទាំងអស់ ។ ហើយជិនាន់យើងបែកភ្នំពេញវៃលន់ នល់ ដាច់ហើយ ដែលយើងខ្មែរក្រហម វៃទៅនៅនឹង គាត់ឡើងក្តាប់ពាណិជ្ជកម្មរដ្ឋ ក្រសួងពាណិជ្ជកម្មទាំងអស់ ប៉ុនគេចាប់ជិនាន់ ៧៦ ។

ដានី ៖ ចុះកាលនឹងដល់ពេលណាបានមានកងពល?

សុន ៖ កងពលឆ្នាំ៧៤ ៧៥ហើយ មានកងពល ។

ដានី ៖ ខាងកងពលទីប៉ុន្មាន?

សុន ៖ ខ្ញុំកងពលទី២ ។

ដានី ៖ កងពល កាលនឹងនៅភូមិភាគ៣០៤មាន៣កងពល?

សុន : ពាក់ពល ទី១ ទី២ ទី៣ ។

ដានី : ទី១ពីណាគេ?

សុន : ទី១អឿន ស្អីអឿន ។

ដានី : បាទ! តាអឿន ។

សុន : ទី២នឹងឈិន១ សយគេចាប់អស់ហើយ ។

ដានី : បាទ! ទី៣?

សុន : ទី៣ឈ្មោះស្អីទេ ខ្ញុំ ។

ដានី : ស្អួននឹងមិនមែន?

សុន : បាទ! ស្អួននឹងមិនដឹង ហើយស្អីមួយទៀត ។

ដានី : ចឹងពាក់ពល ។ ដល់ពេលមុខព្រួញ ដែលយើងវៃឆ្នាំ៧៤នឹង យើងមកព្រែកក្តាម?

សុន : វៃព្រែកក្តាម ដល់ឆ្នាំ៧៥វៃចូលភ្នំពេញ ពួកខ្ញុំមុខសញ្ញាខ្ញុំវៃចូលពីលិចភ្នំពេញ ពីទួលគោក ទៅ ពីឃ្លាំញប៉ាយ៉ាប ។

ដានី : ពីបឹងប៉ាយ៉ាប ពីអីនឹង?

សុន : បាទ! បឹងប៉ាយ៉ាប ពីភ្នំអង្គរស្ស ខត្តផ្អី ព្រែកត្នោពួកខ្ញុំ ឆ្លាយកងពលយើងខាងខត្តទាំង អស់ ។

ដានី : ដែលខាងមុខព្រួញភ្នំបាសិត ខាងអីពួកងពលទី១?

សុន : បាទ! អានឹងអត់ទេ ពួកខាងភូមិភាគពិសេស នឹងខាងលិចភ្នំពេញ ។ ខាងពួកតាសាន ពួក អីនឹង តាសានភូមិភាគពិសេស ។

ដានី : តាសាន?

សុន : តែពួកខ្ញុំចាប់ដៃគាត់ ។

ដានី : វៃយូរដែរ បានចូលដល់ភ្នំពេញ?

សុន : វៃ បើគិតទៅម៉ាខែ១៤១នឹង៧៥នឹង ដូចថាម៉ាខែនឹងចូល ។

ដានី : កាលនឹងដូចយើងសហការគ្នាថាភូមិភាគពិសេស ភូមិភាគ៧៥០?

សុន : បាទ! សហការគ្នាទាំងអស់ម៉ាជុំគ្នានឹង វៃតាំងពីម៉ោងពេលវៃផ្ទុះអីស្មើគ្នាទាំងអស់ ។

ដានី : ដល់ពេលវៃចូលភ្នំពេញ វៃចូលព្រមគ្នា ឬក៏មានខាងមុខព្រួញណាចូលមុន ចូលក្រោយ?

សុន : ដូចព្រមគ្នាកាលនឹង គ្រាន់ចូល១ព្រមគ្នាជុំវិញទាំងអស់ ។

ដានី : ចូលទៅព្រមគ្នាជុំវិញទាំងអស់?

សុន ៖ បាទ! ពួកខ្ញុំនឹងចាប់ពីព្រែកព្នៅមកទល់នឹងវ៉ារទេះភ្លើងមកកន្លែងទួលគោក ។ កន្លែងវ៉ា អានឹងចាប់ដៃខាងភូមិភាគពិសេស ជិតពោធិ៍ចិនតុងជិតអីអានឹងភូមិភាគពិសេសហើយ មុំឃ្នាញវត្តឃ្នាញវត្តអីនឹងពួកខ្ញុំ ។

ដានី ៖ របស់តាសារឿន?

សុន ៖ បាទ! ផាប់ច្រើនដែរ ។

ដានី ៖ ស្គាល់តាសារឿនទេ?

សុន ៖ ស្គាល់ តាសារឿន តាសានអីជាមួយគ្នានឹង ។

ប្រពន្ធ ៖ បង០៦ តាសាន ។

សុន ៖ ០៥ ដូចគ្នា ហ្នឹងសុទ្ធតែគ្នាគាត់នៅខាងភាពពិសេស ពួកម៉ាក់គាត់ដំបូង ។

ដានី ៖ ចុះដល់ពេលវៃចូលទៅ ពូនៅខាងវ៉ារទេះភ្លើងនឹង?

សុន ៖ បាទ! ចូលទៅទំនប់ទួលគោក ផ្ទះខ្ញុំទៅនៅមុំជិតសាលាអីគេ សាលាវិទ្យាល័យ កាលនឹងទួលគោកនឹង ។

ដានី ៖ ឥន្ទ្រទេវី?

សុន ៖ បាទ! បែបនៅមុំត្រង់នឹង ព្រោះខ្ញុំនៅមុំនឹងហើយ មុំសាលានឹងជាប់ទំនប់ ចាប់ពីទំនប់ចឹងទៅទល់នឹងបង្គោលអង់តែនទូរទស្សន៍ម៉ាជួរនឹងនៅចេះមកទល់វ៉ា ទៅចេះមកទល់ស្ពាតចាស់ស្ពាតអីពួកខ្ញុំនៅ បែកមុខសញ្ញាគ្នា ។

ដានី ៖ ពូនៅបានយូរដែរ នៅភ្នំពេញ?

សុន ៖ នៅបានម៉ាខែ ។

ដានី ៖ នៅបានម៉ាខែ?

សុន ៖ បាទ! នៅបានម៉ាខែចឹង គេឲ្យមកនៅស្អន់ៗនឹង មកនៅខាងជើងភូមិគេហៅភូមិស្អីទេ ហួសស្អន់ទៅទៀត មកឃើភ្លេច មកខាងកំពង់ធំមក តាមផ្លូវហួសស្អន់មកគេហៅស្អីទេ ។ ខ្ញុំមកនៅគេឲ្យធ្វើផ្ទះ រកស្លឹករកឈើអី គេប្រុងធ្វើស្រែនៅនឹង ។ ស្រាប់តែគេហៅចូលភ្នំពេញវិញ អត់ទាន់បានធ្វើផ្ទះទេ គេហៅចូលភ្នំពេញវិញ គេរៀបចំឲ្យឡើងឋានៈ ។

ដានី ៖ ចឹងដំបូងពេលបែកភ្នំពេញឆ្នាំ៧៥ ពូបានចូលទៅនៅបានម៉ាខែ?

សុន ៖ ទៅបានម៉ាខែ ។

ដានី ៖ ម៉ាខែគេធ្វើអីទៅនៅនឹង?

សុន ៖ គ្មានធ្វើអី គេដើររៀបផ្ទះរៀបអីនឹង ដូចថាផ្ទះវ៉ារញ៉ោវញ៉ៃអីចឹងគេឲ្យរៀបផ្ទះរៀបអីចឹង ។

ដានី ៖ គេឲ្យយើងបោសសំអាត?

សុន ៖ បោសសំអាតផ្ទះ ខោអាវទូអីគេឲ្យរៀបតាម អាអ្នករៀបៗ អាអ្នករើៗ ។

ដានី ៖ អ្នករើដែរ?

សុន ៖ បាទ! មានអ្នកខ្លះគេរើរកនេះរកនោះ ។

ដានី ៖ អ្នកយើងរើរក សម្ភារៈដូចជាមាសពេជ្រអី?

សុន ៖ បាទ!

ប្រពន្ធ ៖ មាសអីមានណា អត់ឲ្យយកផងនឹង មាសទាំងដុំៗគាត់កាន់មក ។

សុន ៖ ជំនាន់នឹងគេមិនឲ្យយក ។ ខ្ញុំនៅបានម៉ាខែឡើង ដល់ឡើងមកក្រចេះ ឡើងមកមណ្ឌលគិរី នឹងជិះកាណូតទេ ពួកខ្ញុំ ។

ដានី ៖ មកស្គន់ៗនៅបានរយៈពេលប៉ុន្មានបាន?

សុន ៖ ស្គន់នៅមិនទាន់បាន ជាម៉ាខែចុះគ្រាន់រៀបចំដែលស្លឹកអីយើងដូចជា ទិញស្លឹកទិញអីឲ្យប្រជាជនដេរស្លឹកដេរអី រកឈើប្រុងនឹងធ្វើផ្ទះនៅ គេឲ្យឡើងមកវិញ ។

ដានី ៖ អូ! ដល់ពេលឡើងមកភ្នំពេញគេរៀបចំ?

សុន ៖ រៀបចំឲ្យឡើងមក ។

ដានី ៖ គេរៀបចំជាយ៉ាងម៉េច រៀបចំជា?

សុន ៖ រៀបចំដូចថាចែកកងនោះ ត្រូវកងនេះទៅខាងការពារអី ពួកខ្ញុំដំបូងកងពលពួកខ្ញុំនឹងត្រូវទៅនៅជើងទឹកទេ ឈិននឹង ។ តែគាត់សុំ គាត់សុំទៅខាងមណ្ឌលគិរីៗ ។

ដានី ៖ តាឈិនសុំទៅ?

សុន ៖ បាទ! សុំទៅ ។

ដានី ៖ មុនដំបូងគេឲ្យគាត់ទៅខាងជើងទឹក?

សុន ៖ មុនដំបូងទៅខាងសមុទ្រនោះ កុំអីទៅខាងសមុទ្រខាងកំពង់សោមខាងអីខាងជើងទឹក ។ ដល់ចឹងគាត់សុំទៅ ដូរកងពលណាទៅជើងទឹក ខ្ញុំឡើងទៅនឹង ។

ដានី ៖ កងពលរបស់ខាងនិរតី កងពលតាម៉េតស្គាល់តាម៉េតអត់?

សុន ៖ ឮតែឈ្មោះ អត់ស្គាល់ ។

ដានី ៖ អូ! ប្រទ្បាំតាមុត មាស មុត កងពល១៦៨ គាត់នៅខាង?

សុន ៖ បាទ! ស្គាល់តែឈ្មោះទេ ខ្ញុំអត់ដែលឃើញមុខគាត់ ។

ដានី : ចឹងដល់ពេលចឹងទៅ កងពលនឹងគេរៀបចំជាដដែល ឬក៏គេមានការផ្លាស់ប្តូរអីម៉េចដល់ពេលយើងរៀបចំឡើងមកធ្វើការ?

សុន : ឡើងមកមុនដំបូងអត់មានការផ្លាស់ប្តូរអីទេ ទាល់តែយើងនៅយូរម៉ង ប្រហែលជាខ្ទង់ ។

ដានី : អត់ទេ ខ្ញុំចង់ដឹង កាលពីមុនយើងមិនកងពលទី២សមាសភាពកងពលទី២ទាំងអស់យើងឲ្យមកមណ្ឌលគិរី ឬក៏មានបញ្ចូលខាងអីបង្កើតជាកងពលថ្មី?

សុន : អត់ៗមានបង្កើតផង កម្លាំងដដែល ។

ដានី : កម្លាំងដដែល?

សុន : បាទ! កម្លាំងនៅក្នុងកងពលដែលធ្លាប់វ៉ៃភ្នំពេញនឹង ចឹងកម្លាំងនឹងឡើងមកដដែល ។

ដានី : ឡើងមកដដែល?

សុន : បាទ! ឡើងមកមណ្ឌលគិរី ។

ដានី : ទាំងអស់ម៉ង ទាំងម៉ាកងពល?

សុន : ទាំងអស់ម៉ាកងពលនឹងវា៣វរសេនាធំ ។

ដានី : ៣វរៈសេនាធំ?

សុន : បាទ! ជំនាន់នឹងកម្លាំងពេញៗ ម៉ាវរសេនាតូចមាន៤អនុសេនាធំ ។

ដានី : ហើយកាលនឹងជិះប៉ុន្មានកាណូតទៅ?

សុន : ខ្ញុំមិនចាំទេប្អូន ប៉ុនច្រើនណាស់ ច្រើនកាណូត កន្លែងពាណិជ្ជកម្មរដ្ឋ ក្រសួងពាណិជ្ជកម្មកាណូតពាណិជ្ជកម្មដឹកទាំងអស់ ។

ដានី : ខែប៉ុន្មានទៅនឹងខែ?

សុន : ខ្ញុំអត់ចាំដែរ ប្រហែលជាខ្ទង់ខែ៥ ខែ៦ដឹង ។

ដានី : ព្រោះបែកៗរំដោះបានភ្នំពេញថ្ងៃ១៧មេសាឆ្នាំ៧៥ ១៧ខែ៤?

សុន : បាទ! ១៧មេសានឹង ខែ៤ ខ្ទង់៦ ខែ៥ ខែ៦នឹង ព្រោះខ្ញុំឡើងដល់ក្រចេះចឹង ធ្វើដំណើរពីក្រចេះទៅមណ្ឌលគិរី ឡានវាជាប់ផុងនោះ ខែភ្លៀងហើយ ។ ចឹងទ័ពអត់បាយតាមព្រៃតាមអីនឹង ឡានដឹកអង្ករឲ្យអត់បាន ទៅពាក់កណ្ដាលព្រៃទៅអត់រួចបកមកវិញទៅចូលក្រចេះម៉ាសារ ។ បានម៉ាសារទៀតឡើងខែប្រាំង នៅក្រចេះរៀនសូត្រនៅក្រចេះនឹងចង់ម៉ាឆ្នាំ ។

ដានី : រៀននៅក្រចេះនឹង?

សុន : បាទ! រៀននៅក្រចេះ នៅយូរ ។

ដានី ៖ នៅទីក្រុងក្របេះនឹងតែម៉ង?

សុន ៖ នៅនឹងផ្សារម៉ង ហើយខ្ញុំនៅក្របេះចាញ់មហាចាញ់ ខ្ញុំផ្សារក្របេះនៅអត់បាននៅញាក់រាល់ថ្ងៃចាញ់ ។ ដល់ឡើងផុតក្របេះទៅអត់ចាញ់ ។

ដានី ៖ នៅក្របេះរយៈពេលប៉ុន្មានទៅបានទៅដល់?

សុន ៖ នៅយូរទាល់តែប៉ុន្មានខែ ទាល់តែនិយាយទៅទាល់តែដាច់ឆ្នាំ ខែ១ ៧៦ ។

ដានី ៖ ខែ១ ៧៦?

សុន ៖ បាទ! បានឡើងៗម៉ាសារទៀតអត់ឡើងតាមផ្លូវនឹង ឡើងទៅខាងផ្លូវទៅស្នួលបេះវិញ ឲ្យទៅឆ្លងព្រែកទេទៅ គេហៅភ្នំព្រេចភ្នំអី បើកកាត់ភ្នំ ផ្លូវភ្នំព្រេចនឹងចេញទៅមណ្ឌលគិរីតែម្តង ឡានដែរ ប៉ុន្តែវាអត់មានដាប់មានអីទេ វាខែប្រាំង ខែ១ ឡើងទៅដេកព្រៃម៉ាយប់ស្អែកឡើងបានដល់ព្រំដែន ។

ដានី ៖ ចឹងនៅក្របេះយើងអត់ធ្វើអីទេ នៅតែរៀនសូត្រ?

សុន ៖ នៅរៀនសូត្រ ជំនាន់នឹងឆ្លងជីវទស្សន៍ស្អីគេរៀនសូត្រជីវទស្សន៍ជួយមតិអីគ្នាម៉ាជំនាន់នឹង និយាយទៅ អត់មានទំនេរ រៀនរហូត ។

ដានី ៖ គេមានធ្វើប្រវត្តិរូប សួរនាំ?

សុន ៖ បាទ! មានធ្វើប្រវត្តិរូប សួរពីវណ្ណៈភាព សួរពីស្អី ។ ខ្ញុំនៅនឹង ខ្ញុំសុំគេឲលេងផ្ទះគេអត់ឲ្យទៅ ។

ដានី ៖ គេឲ្យទៅ ជិតដែរ?

សុន ៖ បាទ! ខ្ញុំគ្មានឆ្ងាយអី ។

ដានី ៖ បានចេញមកឆ្លងទូកដ ចេញព្រែកប្រសព្វជិះមក?

សុន ៖ ពួកដែលកងខ្ញុំនឹង គេឲ្យខ្ញុំមកធ្វើត្រីចឹងតាមកង គេរើសអ្នកមកធ្វើត្រីធ្លង់បីបាងនៅតាម៉ៅក្រហម-កនេះ ពួកនឹងវាទៅលេងដល់ភូមិខ្ញុំ ។ ប៉ុន្តែខ្ញុំសុំទៅ ខ្ញុំនៅជាមួយកងវរៈនៅកាន់តេអូកាន់ស្អីនឹង ។

ដានី ៖ និរសាហើយម៉េច?

សុន ៖ នៅដូចថាកាន់អាគ្រឿងចឹងៗ មិនមែននិរសាទេ កាន់តេអូ កាន់អីចឹងទៅ ដល់នេះគេអត់ឲ្យដើរ គេថាចាំទៅជាមួយគេ កងវរៈនឹង ។

ដានី ៖ នៅផ្ទាល់ៗជាមួយ?

សុន ៖ បាទ! កងវរៈៗនឹង ប្រពន្ធនៅស្រុកនៅនឹងដែរ គេថា«ចាំអញទៅលេងផ្ទះប្រពន្ធគាត់ចាំឯងទៅ» ។ ដល់ទៅម៉ាថ្ងៃ ជាម៉ាថ្ងៃមិនដឹងជាគេករខ្ញុំម៉ាថ្ងៃៗ គាត់នោះក៏អត់បានទៅដែរ ទៅគេហៅឡើងទៅទៀតទៅ ថ្ងៃ១ ៧/៦ ខែ១ ។

ដានី ៖ ចឹងកាលនៅក្រចេះនឹងយើងទាក់ទងអីជាមួយខាងតំបន់ក្រចេះដែរ?

សុន ៖ តំបន់ក្រចេះនឹង
ដូចអត់មានទាក់ទងអីយើងគ្រាន់ទាក់ទងខាងគេតំបន់គេយើងស្នាក់នៅចឹង ។

ដានី ៖ តែអត់មានធ្វើការជាមួយពួកតំបន់ទេ?

សុន ៖ បាទ! អត់មានធ្វើការទេ គ្រាន់តែរស់នៅនឹង រៀនសូត្រនៅនឹងហាត់ៗរាល់ថ្ងៃរាល់យប់ ។

ដានី ៖ ក្រចេះតំបន់ឯករាជ្យ ឬតំបន់ស្ម័យត ឬក៏តំបន់?

សុន ៖ ក្រចេះកាលនឹងដូចតំបន់ស្វ័យត ក្រចេះដូចអត់មានដល់ភូមិភាគណាទេ ដូចតំបន់ស្វ័យតទេ កាលនឹង ។

ដានី ៖ ចឹងដល់ពេលយើងធ្វើដំណើរមកមណ្ឌលគិរី យើងមកស្នាក់នៅកន្លែងណាកងពល?

សុន ៖ ខ្ញុំមកដំបូងនៅ យកទៅនៅម៉ាវរៈខ្ញុំទៅដល់កន្លែងនៅមុនគេ ត្រង់នឹងនៅកណ្តាលព្រៃនឹងវា មានបន្ទាយចាស់ បន្ទាយជំនាន់ទាហានពីដើម ។ ចឹងគេថាកងពូឯងនៅនឹងទៅដល់ចុះទៅ នឹង ។

ដានី ៖ នៅណាគេហៅអីអានឹង?

សុន ៖ ត្រង់នឹងគេហៅស្លែគេ ពពួកដូវាំងយាអីគេ ពាក្យជនជាតិ ត្រង់នឹងនៅក្នុងព្រៃ ។

ដានី ៖ ម្តុំអីគេម្តុំនឹង?

សុន ៖ នឹងវាចូលក្នុងខេត្តមណ្ឌលគិរីហើយ ប៉ុន្តែស្រុកនៅក្នុងស្រុកអូររាំង ។

ដានី ៖ ស្រុកអូររាំង?

សុន ៖ បាទ! គ្រាន់ទីតាំងនឹងហៅពពួក ។

ដានី ៖ នៅជាប់ព្រំដែន ហើយអត់ទេ?

សុន ៖ អត់ទេ នៅឆ្ងាយៗព្រំដែនៗបួននៅត្រង់នឹង ឡានជិះចង់ម៉ាថ្ងៃទៀតបានដល់ព្រំដែន ។ បាទ! ប៉ុនថាកន្លែងក្រោយៗគេគ្រាន់នៅកន្លែងក្រោយ កន្លែងបន្ថុបន្ថើនដលនៅក្រោយ ប៉ុនដល់ពេលនេះទៅព្រំដែនគេរើសកម្លាំងទៅទៀត ។

ដានី ៖ ហួសពីកែវសីម៉ាទៅឆ្ងាយ?

សុន ៖ ហួស បាទ!កែវសីម៉ានឹងក៏កងពួកខ្ញុំនៅដែរ ប៉ុនថាវរៈផ្សេងគ្នាកងវរៈសេនាធំ ។

ដានី ៖ ដល់មន្ទីរកងពលនៅណាទៅ?

សុន ៖ មន្ទីរកងពលនៅកោះញែក ។ ទីរួមស្រុកជំនាន់៣ឆ្នាំនោះនៅកោះញែក មិនមែននៅទីរួមស្រុកឥឡូវទេ ។

ដានី ៖ ទីរួមខេត្ត?

សុន ៖ អឺ! បាទ!ទីរួមខេត្ត ។

ដានី ៖ ទីរួមខេត្តនៅកោះញែក?

សុន ៖ នៅកោះញែក ។

ដានី ៖ ចឹងឆ្ងាយៗពីកន្លែងពូទៅ?

សុន ៖ ឆ្ងាយជិះម៉ាថ្ងៃ ទៅរៀនអីជិះម៉ាថ្ងៃ ។

ដានី ៖ ខស្សាហ៍ទៅដែរ?

សុន ៖ បាទ! ខ្ញុំទៅរៀនញឹកកន្លែង ។

ដានី ៖ ពូមានឋានៈអីដែល ដល់ពេលទៅ?

សុន ៖ ខ្ញុំនឹងអនុសេនាធំកាលនឹង ។

ដានី ៖ អនុសេនាធំដូច?

សុន ៖ ម៉ាកងខ្ញុំនៅព្រំដែន តែម៉ាកងខ្ញុំនឹងឯង ។

ដានី ៖ យើងកាលនឹង អនុសេនាធំពូខាងអី ខាង?

សុន ៖ ការនិយាយទៅ អនុសេនាធំខ្ញុំ ដូចថាគេចំរាញ់យកទៅយកតែកងផ្សេងៗ និយាយទៅដូចគេជ្រើសរើសចំរាញ់ អាខ្លះនឹងទៅបានម៉ាកំណាត់ថ្ងៃ ម៉ាថ្ងៃអីគេយកមកវិញ ។

ដានី ៖ យកទៅណា?

សុន ៖ យកមកនឹង យកមកនៅក្រោយនឹងទេ គ្រាន់តែឲ្យនៅព្រំដែន នៅធ្វើការអត់កើតទេជំនាន់នោះ ឧទាហរណ៍ថាយើងដើរនឹងគ្នាទទួលខុសត្រូវ ដូចថាជាតិសាសន៍ស្អី និយាយពីចេះចុះ របៀបថានិយាយថាយើងខ្លាចយួន ខ្លាចស្អីចឹង ឃើញគ្រាប់ ឬក៏យើងនិយាយអីទៅមិនចំណេញ នឹងគេអត់ទុកទេ ។ ដល់ចឹងគេចំរាញ់កម្លាំងបានម៉ាអនុសេនាធំចឹង ខ្ញុំនៅនឹងចាំ ។ ហើយមានកងវរៈនៅជាមួយ ។

ដានី ៖ ចុះដូចថានៅជិតបងប្អូនជនជាតិដែរ?

សុន ៖ នៅជាមួយគ្នា ។

ដានី ៖ នៅជាមួយគ្នាដែរ?

សុន ៖ បាទ! គេមានកម្លាំងការពារដំបូង នៅដំបូងពេញម៉ាឆ្នាំនៅជាមួយគ្នា ប៉ុនគ្រាន់ហូបបាយអីផ្សេងគ្នា ប្រជុំជីវភាពអីផ្សេងគ្នា ។

ដានី ៖ គាត់ខាងបងប្អូនជនជាតិអីគាត់ខាងពួករបស់ភូមិភាគ?

សុន ៖ ខាងតំបន់ ។

ដានី ៖ តំបន់អី?

សុន ៖ ខ្ញុំអត់ស្គាល់ទេ តំបន់នឹងមិនដឹងតំបន់អី ។

ដានី ៖ តំបន់១០០ប៉ុន្មានដែរ?

សុន ៖ បាទ! ខ្ញុំអត់ស្គាល់ ដូចអត់ចាប់អារម្មណ៍សួរតំបន់គេកាលនឹង ។

ដានី ៖ ចុះភូមិ អ្នកភូមិជនជាតិនៅជាមួយនឹងជិតៗនឹងដែរ?

សុន ៖ នៅព្រំដែន អត់មានភូមិនៅជិតនឹងទេ ។

ដានី ៖ អត់មានភូមិ?

សុន ៖ ដល់មកជិះឡានម៉ាកំណាត់ថ្ងៃ ឬម៉ាថ្ងៃបានដល់ភូមិ ។

ដានី ៖ សុទ្ធតែព្រៃ?

សុន ៖ សុទ្ធតែព្រៃភ្នំ ។

ដានី ៖ តែអត់អីដែរ អត់ចាញ់?

សុន ៖ អត់ចាញ់ទេ ខ្ញុំនៅអត់ចាញ់ផងកាលនឹង បើវាភ្នំច្រើន ប៉ុនវាអត់សូវមានព្រៃ ភ្នំវាលៗ ។ បើចាញ់ៗអ្នកក្រោយ ចាញ់ ។

ដានី ៖ នៅក្រោយណាវិញ?

សុន ៖ នៅ អ្នកនៅធ្វើស្រែធ្វើអី ព្រោះខ្ញុំនៅព្រំដែនអត់មានធ្វើស្រែធ្វើអីទេ ចឹងយើងដើរទៅធ្វើការតាមព្រំដែន ហើយអ្នកនៅក្រោយនឹងធ្វើស្រែផងអីផង បង្កបង្កើនផលដើម្បីចិញ្ចឹមអ្នកមុខ ។

ដានី ៖ ធ្វើការនឹង ធ្វើការយ៉ាងម៉េច យើងទៅធ្វើការជាមួយយួន ឬក៏យើងវ៉ៃ?

សុន ៖ ទៅដំបូងយើងចចារធ្វើការសហការគ្នាជាមួយយួន ប៉ុន្តែដល់ឧទាហរណ៍ថាយើងធ្វើការចឹងទៅយើងមិនមានដែនទីវៀងខ្លួន យើងកំណត់ថាត្រង់នេះដីយើងចឹងទៅ ដល់គេៗមានដែនទីគេដែរ ។ ដល់ចឹងដែនទីវាអត់ ដែនទីយើងវាមិនត្រូវគ្នាទេ ចឹងយើងតែថាដីយើងនោះគេថាដីគេនេះ ដល់ចឹងយើងចចារយកចំនុចមួយឲ្យត្រូវគ្នា អត់ត្រូវ ។ បាទៗ! ចឹងកើតវ៉ៃ គ្នាៗ ត្រឹម៧៦វ៉ៃគ្នា ។

ដានី ៖ ៧៦ រឺគ្នា?

សុន ៖ បាទ! ទៅត្រូវគ្នាស្រួលម៉ាឆ្នាំដំបូង ៧៥ ដល់៧៦ចុងឆ្នាំ៧៦នឹងរឺឌុបៗកន្លែងខ្លះរ៉ឺ កន្លែងខ្លះអត់ចឹងៗ កន្លែងខ្លះរ៉ឺនឹង លែងទាក់ទងគ្នាបាន អត់ឲ្យឃើញមុខគ្នាទេៗ

ដានី ៖ អត់ឲ្យឃើញមុខ?

សុន ៖ បាទ! ដល់កន្លែងផ្សេងយើងនៅសហការនៅអីគ្នាបាន ដល់កន្លែងរ៉ឺអត់ៗ ដល់មក៧៧ អានឹងសុទ្ធមែនទែន សុទ្ធតែនេះទៅៗ

ដានី ៖ ប៉ុន្តែពូខស្សាហ៍ទៅប្រជុំនៅទីកន្លែងពលដែរ?

សុន ៖ ទៅសឹងថា ម៉ាខែ២ខែទៅម្តង គេហៅទៅញឹក ជិះឡានម៉ាថ្ងៃកាត់ព្រៃទម្រាំដល់ៗ

ដានី ៖ ទៅប្រជុំជាមួយតាឈិននឹង?

សុន ៖ បាទ! តាឈិន ជាមួយសយតាសយៗ ៗ

ដានី ៖ តាសយ ពេលនឹងតាឈិនប្រធាន ឬតាសយប្រធាន?

សុន ៖ តាឈិនប្រធានៗ

ដានី ៖ តាឈិនប្រធាន សយអនុៗ

សុន ៖ សយអនុ គាត់កាចណាស់ តាសយៗ

ដានី ៖ គាត់កាច?

សុន ៖ បាទ! តាឈិនស្លូតទេ គាត់អត់សូវមាត់សូវ-ក ប៉ុនតាសយមិនបានទេ កាចណាស់ៗ

ដានី ៖ ស្គាល់គាត់ច្បាស់?

សុន ៖ បាទ!ស្គាល់ច្បាស់បើទៅរៀនរហូតៗ

ដានី ៖ គាត់អ្នកស្រុកណា?

សុន ៖ កំពង់ចាមទាំងអស់តាសយ តាឈិន ក៏នៅកំពង់ចាម នៅតាឈិនគាត់នៅព្រៃឈរខ្ញុំដឹង ចាំប្រហែលច្បាស់ ប៉ុនគាត់អ្នកនៅកំពង់ចាមៗ

ដានី ៖ សយ?

សុន ៖ សយអីក៏នៅនឹងៗ ប៉ុន្តែតាឈិនពេលទៅរៀនសូត្រអីបង្រៀនទ័ពពីព្រំដែនទៅ គាត់មិនអ្នកបង្រៀនទេ ព្រោះគាត់នយោបាយនិយាយអីគាត់អត់សូវចេះទេ អក្សរគាត់អត់ចេះផងនឹង បាទ!គ្រាន់ចេះបានអានខ្លះៗ បើតាសយបានគាត់បង្រៀនៗ

ដានី ៖ តាសយបង្រៀន?

សុន ៖ បាទ!

ដានី ៖ តាឈិនគាត់ធ្វើអី?

សុន ៖ គាត់ហ្នឹងបើនិយាយទៅប្រធានកងពលនឹង ។

ដានី ៖ ប៉ុន្តែគាត់?

សុន ៖ បាទ! រៀនសូត្រអីតាសយទេ បង្រៀន ។

ដានី ៖ បង្រៀន?

សុន ៖ បាទ! សយកាចណាស់ ។

ដានី ៖ គាត់កាចយ៉ាងម៉េចទៅ?

សុន ៖ បើថាខុសហើយ ដែលថាបញ្ញាឲ្យវ៉ៃហើយ គាត់វ៉ៃហើយវ៉ៃចោល ។

ដានី ៖ ចឹង?

សុន ៖ បាទ!

ដានី ៖ គាត់វ៉ៃកូនទាហាន?

សុន ៖ បាទ! នៅធ្វើមិនបានទេ កាច ។

ដានី ៖ អឺ! ដល់ឆ្នាំណាទៅបានគេចាប់ពួកគាត់?

សុន ៖ ឆ្នាំ៧៨ហើយ ។

ដានី ៖ ឆ្នាំ៧៨?

សុន ៖ បាទ! ដើមឆ្នាំ៧៨ ចុង៧៧គេចាប់ ។ ថាទៅប៉ុឈិនគេចាប់ក្រោយគេបំផុត ។

ដានី ៖ ឈិនចាប់ក្រោយ?

សុន ៖ បាទ! ចាប់ដូចថាថ្នាក់ភូមិភាគ ថ្នាក់តំបន់នេះ ចាប់អស់ហើយ តាឈិននេះចាប់ក្រោយ ។ តាសយនេះចាប់មុនទៀត តាឈិននេះក្រោយទៀត ប្រធានកងពលនឹង ប៉ុន្តែតាសយចាប់ មុន ។

ដានី ៖ តាសយគេចាប់មុន?

សុន ៖ គេនិយាយ ប៉ុនយើងមិនដឹងអីទេប្អូន បើកាលនឹងគេនិយាយថា បើគេរៀបចំបក្សគេនឹង ជាចំហរតាឈិននឹងធំ ប៉ុន្តែក្នុងបក្សគេនឹងដូចថាគេប្រុងសើរើនឹងសយធំជាង គេនិយាយ ចឹង ។

ដានី ៖ តែចុះពួដូចថាពួមានតួនាទី ដែលយើងជាកម្មាភិបាលមួយដែរ ដែលជាអនុសេនាធំចឹងដែរ យើងខ្សែជាមួយតាឈិន តាសយដែរ យើងអត់ៗមានគេមក?

សុន : គេចាប់ដែរ គេគិតតាមខ្សែតាមអីថាចាប់ស្មើរតែទាំងអស់និយាយម៉ាកងនៅតែខ្ញុំមួយគេពិសោធន៍អស់អាចម៍អស់នោមដែរ ។

ដានី : ចឹង?

សុន : បាទ! គេដូចថាយើងអត់មានសកម្មភាពអីគួរឲ្យគេចាប់បាន គេចាប់ដែរ ប៉ុនគ្រាន់គេពិសោធន៍អស់អាចម៍អស់នោមហើយខ្ញុំ ។ បាទ!គេឲ្យចាប់គ្នាឯងក៏ចាប់ដែរ ខ្ញុំចាប់ គេនៅពីលើៗខ្ញុំទៀត ប្រធានដូចថាអនុសេនាធំមានប្រធានមានអីចឹងទៅ ខ្ញុំក្រោមគេទេ អនុសេនាធំដែរ ប៉ុនវាមានប្រធានអនុប្រធាន សមាជិក ។ ដល់ចឹងគេឲ្យចាប់ហើយសុទ្ធតែអាអ្នកនៅរួមបាយរួមអីជាមួយយើង តែបើយើងធ្វើអត់បាន អានឹងក៏គេចាប់យើង ។ តែខ្ញុំម៉ាសារនឹងសុទ្ធតែធ្វើបានទាំងអស់ ។ ហើយខទាហរណ៍ចូលទៅវ៉ៃនៅព្រំដែននឹងគេប្រគល់ដូច ថាគេចង់សាកយើង និយាយទៅគេចាប់ម៉ាខ្សែតាឈិន ចាប់ទាំងអស់ហើយរំលាយអ្នក កម្មាភិបាលម៉ាខ្សែជំនាន់តាឈិនដឹកនាំនឹង រំលាយចោលទាំងអស់ ។ ដល់ពេលនេះយកពី ៣០១ទៅក្តាប់នឹង គេប្រើយើងធម្មតា ប៉ុនសិទ្ធិអំណាចគេរំលាយអស់ហើយ ។ ប៉ុនដល់ ពេលយើងធ្វើល្អវិញទៅគេទុកដើមវិញឲ្យធ្វើ គេដូចថាយើងមានសិទ្ធិអី អនុសេនាធំ ឬ អនុសេនាតូចចឹងគេពិសោធន៍យើងអស់អាចម៌អស់នោះ ថាយើងអត់មានក្បត់មានអី ឬការពារគេគេឲ្យនៅធ្វើប្រព័ន្ធយុវកកបក្សអីគេរំលាយទាំងអស់ ។ ដល់ពេលគេចូលដឹកនាំដឹងថាយើងល្អបានគេបញ្ចូល ដឹកនាំចូលបក្សគេ ។

ដានី : ចឹងកម្មាភិបាលដែលដូចយើងកម្មាភិបាលចាស់មកពីជំនាន់តាឈិន តាសយអីនឹង ចាប់ពីខានះត្រឹមណាដល់ត្រឹមណាទៅដែលគេចាប់ ភាគច្រើន ។

សុន : ចាប់ពីប្រធានក្រុមទៅ ។

ដានី : ចាប់ពីប្រធានក្រុមទៅ?

សុន : បាទ! ចាប់ស្មើរទាំងអស់ ។

ដានី : ដូចឋានះប្រហែលៗពូអ្នកដែលរួចច្រើន?

សុន : ទេ! ភាគតិចណាស់នៅរស់ បើម៉ាកងខ្ញុំម៉ាសារនឹងនៅព្រំដែននៅតែខ្ញុំមួយ ក្រៅពីនឹងមកចាប់ទាំងអស់ ខ្ញុំនាំគេមកចាប់មិនចេះតិច ។ ប៉ុនយើងអត់ចាប់ខ្លួនយើងទេ យើងនាំមកគ្រាន់ដាក់ដល់កន្លែងគេ មានកន្លែងគេចាប់ផ្សេង ។ ហើយខ្ញុំនឹងសុទ្ធតែមានគ្នាឯង ដូចថាចុះសុទ្ធតែមនុស្សនៅជាមួយៗគ្នាចឹង ។ ចឹងគេយកមកប្រគល់ឲ្យយើងនាំមកចាប់ ហើយ

កាំភ្លើងខ្ទាហរណ៍ថាទ័ពគេមានកាំភ្លើងមានគ្រាប់បែក គេប្រគល់ឲ្យយើងថាធ្វើម៉េចធ្វើឲ្យតែយើងរៀបចំផែនការស្អាតឲ្យគេ ។ ឲ្យគេចាប់បាន កាំភ្លើងក៏យើងដកខ្លួនយើង គ្រាប់បែកអីក៏យើងប្រមូលមកខ្លួនយើងទាំងអស់ តែយើងមានសិទ្ធិអំណាចតូចជាងទេ ។ ប៉ុន្តែជំនាន់នឹង តែមានបទបញ្ជាថាអីហើយ ទោះបីខ្ពស់ទាបលើយើងក៏អត់ហ៊ានប្រកែកដែរ ។ ចឹងមុននឹងទៅនឹង ខ្ញុំប្រជុំជួរព្រឹកនឹង ខ្ញុំនិយាយ ខ្ញុំថា«យើងត្រូវផ្លាស់ប្តូរគ្នា ចឹងត្រូវយកកម្លាំងពីព្រំដែនទៅៗជួយការងារការដ្ឋានខាងក្រោយអីចឹងៗ កាំភ្លើងសុំដកទាំងអស់ ទាំងគ្រាប់ទាំងរំសេវ ត្រឹមប្រមូលតំរង់ជួរចឹង ។ ប្រមូលហើយ យើងផែកទៀត យើងផែកធ្វើ ម៉េចឲ្យអស់ ។ ចឹងហើយកម្លាំងយើងជូនទៅខ្លួនយើងទៀត ហើយសូម្បីតែអ្នកជូនខ្ញុំ២នាក់ កម្លាំងដែលកងវរៈហៅមកជួប២នាក់ ប៉ុន្តែដឹងការងារចាប់ចងអីនៅតែខ្ញុំមួយទេ អាម្នាក់ ទៀតអត់ដឹងទេ គ្រាន់ជូនអមដំណើរទៅទេ កាំភ្លើងម៉ាដើមម្នាក់ ។ ទៅដល់ប្រគល់ឲ្យគេ យប់នឹងខ្ញុំនៅដេកនឹងយប់នឹងគេចាប់នឹងដែរ គេចាប់ច្រឡំខ្លះដែរ យប់នឹងគេចាប់ដឹងថាច្រឡំដឹងអីគេអត់លែងភ្លាមទេ គេចាប់ចឹង ទាល់តែភ្លឺឡើងគេមើលឃើញមុខច្បាស់បានគេលែង អាចាប់ច្រឡំខ្លះគេចាប់ច្រឡំ ។ ដឹងយកទៅណាៗ ខ្ញុំមិនដឹងដែរ ។

ដានី ៖ ចុះពូទទួលបញ្ជាមកពីណាដែលយើងមានផែនការយើងត្រូវចាប់?

សុន ៖ អានឹងកងវរៈៗគេហៅយើងទៅជួប ។

ដានី ៖ កងវរៈចាស់របស់យើង ឬក៏កងវរៈថ្មី?

សុន ៖ មិនមែនកងវរៈចាស់ទេ គេយកពីកងផ្សេងទៅមកក្តាប់ ។

ដានី ៖ អូ! ៨០១ទៅ?

សុន ៖ បាទ! ៨០១ទៅ ។

ដានី ៖ ពីខាងអី!?

សុន ៖ បាទ! ខាងតាសារឿន ។

ដានី ៖ ខាងតាសារឿន ខាង?

សុន ៖ បាទ! ៨០១ ។

ដានី ៖ ម៉េចបានគេទុកចិត្តពូ ហើយគេប្រគល់?

សុន ៖ មិនដឹងជាយ៉ាងម៉េចដែរ ប៉ុន្តែសកម្មភាពដែលគេធ្វើម៉េចខ្ញុំអត់ដែលប្រឆាំងនឹងគេ ខ្ញុំធ្វើសម្រេចបានទាំងអស់ ។

ដានី ៖ អ្នកផ្សេងគេធ្វើ គេឲ្យធ្វើចិនដែរ ឬក៏យ៉ាងម៉េច អ្នកដូចថាឋានៈដូចពូដែលធ្វើជាប្រធានកង គេធ្វើពិសោធន៍ចិន?

សុន ៖ បាទ! ពិសោធន៍ដូចគ្នានឹង ហើយម៉ាសារនឹងមិនមែនថា គេមិនមែននេះទេ ខ្ញុំក៏ភ័យ គេក៏ភ័យដូចរៀងតែខ្លួននឹង ។ ហើយក៏មិនដឹងថាគេចាប់ថ្ងៃណាទេ ប៉ុនគ្រាន់ថាអំពើដែលយើងប្រព្រឹត្តិយើងខំតែធ្វើល្អនឹង ។

ដានី ៖ តែពូគិតថាកាលនឹងសកម្មដែលគេថាក្បត់ៗយ៉ាងម៉េច ពូគិតថាក្បត់ចិនមែន ឬយ៉ាងម៉េច?

សុន ៖ បើតាមគំនិតខ្ញុំយល់ដូចថា មិនដឹងថាគេក្បត់យ៉ាងម៉េច បើថាការខុសឆ្គងនឹងមានៗ ឧទាហរណ៍មួយ ដែលអានឹងកងជាមួយខ្ញុំ ហ្នឹងនៅដេកនៅកន្លែងយាមធ្វើការយើងមានប៉ុស្តិ៍កន្លែងធ្វើការតាមព្រំដែន មានកន្លែងប៉ុស្តិ៍មួយដើរធ្វើការហើយមកសម្រាកនៅនឹងវិញ ។ ហើយយប់នឹង ខ្ញុំនឹងមានគ្នាម៉ាក្រុមៗ យប់ឡើងយើងចែកមុខសញ្ញាគ្នាដើរធ្វើការ ។ ដល់យប់ឡើងយើងមកដេក ទទួលយប់នឹង អឺ!កងមានគេនោះ គេពីលើខ្ញុំគេប្រធានចិនទៅដល់ចិនយប់ឡើងមានភ្លៀងផងយប់នឹង គេប្រាប់ថា«ដេកមិនបាច់យាមទេចិន» ។ ដល់ចៃដន្យអីយួនវាចូលមក យើងដេកនោះ អត់យាម ចិនវាចូលផ្ទះសំងាត់ជីកក្នុងរូនដីហើយគេដាក់មីន គេដាក់ចំរូងចិនហើយចូលដេកចិនម៉ង ។ ដេកយួនវាចូលមកវាដាក់នៅក្បែរផ្ទះនឹង ផ្លូវចិនយួនវាចូលមកគ្នាវា៧នាក់ វាដាក់មីន២០គ្រាប់ ហើយប្រជុំពីល្ងាចនឹងកងវរៈនឹងហៅមកប្រជុំៗដូចថាយើងទទួលផែនការទាំងអស់ ។ ព្រឹកឡើងក្នុងម៉ាថ្ងៃសុទ្ធតែមានផែនការគេ ក្នុងម៉ាថ្ងៃក្នុងម្នាក់ចាក់ចំរូងឲ្យបាន១៥០០-២០០០ ស្តាយខ្លួនយើងទៅចាក់ខ្លួនយើង ។ ដល់ពេលប្រជុំដាក់ផែនការព្រលឹមឡើងធម្មតាដេកអត់យាមចិនដូចថា ងើបអត់ទាន់ពេលកងវរៈនឹងទៅពីក្រោយទៅដល់មុន ទៅដល់អត់ឃើញមានមនុស្សហៅ អូ!មិនមែនហៅទេទៅដល់នឹងនារសាសែនអាចំរូងនឹងទៅ ឃើញមានមីនយួនវាដាក់ ដល់ចិនស្រែកហៅខ្ញុំភ្ញាក់ឡើងមមីមមើលចិនទៅដាស់គេ ។ ទៅដល់គាត់អត់សួរអាប្រធានពីលើខ្ញុំទេ គាត់សួរខ្ញុំ «មកដល់ពួកឯងដាក់មីន ហើយក៏មីនអ្នកណា» ។ ខ្ញុំមើលទៅខ្ញុំថា«ខ្ញុំអត់បានដាក់ផង» អត់ហ៊ានឆ្លើយ យើងអត់ហ៊ានករថាអីគេជំនាន់នឹង យើងត្រង់ៗ ដល់ចិនវាដាក់អាផ្លូវយើងតែងដើរធ្វើការម៉ាគ្រាប់ទៅ វាដាក់យប់ វាប្រញាប់វាមិនដាក់ជិតអីវាដាក់ចិនទៅមីនគ្រាប់បោចស្មៅគ្រប់ៗមើលទៅឃើញ ។ ដល់ចិនគាត់ដាក់ចំរូងឲ្យនារសាគាត់

ដោះៗអាមីនបានមួយ ហើយផ្លូវទៅចង្ក្រានបាយ២គ្រាប់ទៅ វាដាក់កន្លែងដាំបាយដាំអីវាដាក់ទាំងអស់ កន្លែងដេកយើងចល័តតាមភ្នំអីចឹង ។ ដល់ចឹង“ឯងដេកណាយប់មិញ បានអត់ដឹងយួនចូល? ” ខ្ញុំថា“ខ្ញុំដេកក្នុងផ្ទះសំងាត់” “យាមអត់? ” “អត់យាម”ប្រាប់ត្រង់ចឹងទៅ ។ តែប៉ុននឹងគាត់ហៅមកប្រជុំ ហៅមកទាំងអស់ ផែនការចាក់ចំរូងរំលាយចោលអត់បានទៅចាក់ទេ គាត់ហៅមកប្រជុំថា“ពួកឯង”ចង្អុលមកខ្ញុំថា“ឯងនាំកម្លាំងឯង៣នាក់វាវមីននឹងឲ្យអស់ ។ ហើយអាប៉ុន្មាននាក់នឹងទៀត” វ៉េត វែននឹង គាត់ប្រធានអនុសេនាធំពីលើខ្ញុំ ចឹងគាត់ថា“ឲ្យវ៉េតនាំកម្លាំងនឹងជាមួយពួកតំបន់ទៅតាមវៃយួននឹង ។ យួននឹងដឹងថាយួនវាចូលមកវាទៅវិញវាអត់ទាន់ទៅទេ វាដឹងថាយើងតាម វានៅចាំត្រង់ណា ចឹងគាត់ថាឲ្យតាម គាត់បញ្ជារៀបម៉ាក្រុមខាងប៉ែកនឹងឲ្យទៅតាមវាចូលដល់បន្ទាយអត់ ឬវាសំងំខាងណា ។ ដល់ចឹងឲ្យខាងវ៉េតនឹងទៅ ។ ខ្ញុំនឹងវាវៗគ្នា៣នាក់ វាវម៉ាថ្ងៃនឹងវាវអត់អស់ហើយអាក្នុងផ្លូវៗឡាននឹងវាភ្លៀងនោះ វាដាក់ហើយភ្លៀងទឹកត្រឹមៗនេះ យើងអត់ហ៊ានវាវទេ វាលិចហើយចាំទឹកស្រក់វាវាវតាមនេះ ។ ប៉ុនថាខ្ញុំវាទទួលកន្លែងដែលដូចថាវាអត់មានរឿងទទួលហើយវាអត់មានរឿងជាន់ទៀតណា ។ ដល់ខាងវ៉េតនឹង គេនាំកម្លាំងទៅហើយខ្ញុំខ្សឹបប្រាប់គាត់ ខ្ញុំថាយួននឹងអត់ចូលបន្ទាយទេ អាចវាចាំត្រង់ណា វ៉េតឯងនាំកម្លាំងទៅប្រយ័ត្នគ្រោះថ្នាក់ៗកម្លាំងនឹងរឿងទៀតហើយ ។ ខ្ញុំដឹងថាយើងមានរឿងជាន់ៗយើងខុសហើយ រឿងយួនចូលដាក់មីនម្ដងហើយយើងតាមទៅតែឲ្យប៉ះពាល់កម្លាំងអានឹង រឿងទៀត ។ មកដល់នឹងដូចខ្ញុំថាចឹងយួនវាជិតទៅដល់បន្ទាយវាមានភូមិចាស់មួយនៅលើ ភ្នំនឹង វានៅអង្គុយសំងំចាំនឹងវាមានព្រៃម្ដុំ ។ ហើយយើងតាមគ្នាទៅទាំងវ៉ូងទាំងពួកតំបន់ ផងទាំងពួកយើងជនជាតិអីនឹង ។ នាំទៅមានអីយួនវាដាក់បេមកពីលើមក របួសអស់ប៉ុន្មាននាក់ គ្រាន់តែបាក់ជើង ត្រូវដៃអស់៧នាក់ អានឹងហើយគេចាប់ ។

ដានី : គេថាយើង?

សុន : គេថាយើងអត់ទទួលខុសត្រូវ យើងសេរី យើងក្បត់អីចឹង គេចោទស្រេចតែគេថា បើនិយាយថាក្បត់ដូចមានកំហុសចឹង ។

ដានី : ប៉ុន្តែដូចជាមេធំៗ គាឈិន គាសយអី?

សុន : ដូចគ្មានដឹង ដឹងថាត្រឹមកងវរៈកងអីដឹង ខ្ញុំអត់សួរដឹងដែរអារឿងនឹង គេថាគ្រាន់ថាចំនុចគ្នាខុសចឹងៗវា មើលមនុស្សបើនិយាយទៅវាមិនមែនចង់ចឹងទេ ប៉ុនថាយើងគ្រោះថ្នាក់ ។

ដានី ៖ ចាប់ផ្តើមដូចថាសង្ស័យ ចាប់ផ្តើមគេចោទថាយើងក្បត់ចាប់ពីឆ្នាំណាៗដល់ឆ្នាំណា?

សុន ៖ ៧៧ ៧៨រហូតចេញមក ។

ដានី ៖ ចាប់ផ្តើមមុនគេចាប់តាឈិន តាសយ ឬក៏ក្រោយពីគេចាប់?

សុន ៖ ក្រោយ ៗ ដែលយ៉ាប់មែនទែន គេចាប់តាឈិន តាសយ គេចាប់ម៉ាសារមិនយកអ្នកដឹកនាំទៅថ្មីៗ ចឹងម៉ាសារនឹង យកមក៨០១មក មិនមែនថាអត់ចាប់ទេ ចាប់ទៀត នៅតែមានចាប់ទៀត ចាប់ត ។

ដានី ៖ ដល់ពេលចាប់តាឈិន តាសយទៅ គេយកពី៨០១មក?

សុន ៖ យកពី៨០១ តាសាននីនឹង ។

ដានី ៖ តាសានៗគាត់?

សុន ៖ តាសាននយោបាយ ប្រធានកងពល ។

ដានី ៖ ប្រធានកងពល គេហៅកងពលប៉ុន្មាន?

សុន ៖ កងពល៩២០ដដែល ។

ដានី ៖ ៩២០ដដែល?

សុន ៖ បាទ!

ដានី ៖ ចឹងតាសានគាត់នយោបាយ?

សុន ៖ បាទ!

ដានី ៖ ហើយអនុតាសាន បញ្ជាការយោធា ខាងវ៉ៃ?

សុន ៖ អនុនោះឈ្មោះតាគឹមៗមួយ ណាក់មួយ សុទ្ធតែកងពល ។

ដានី ៖ តាសាន កាលនឹងគេហៅគាត់០៦?

សុន ៖ បាទ! ហៅ០៦ នឹងលេខគាត់ ។

ដានី ៖ លេខ០៦?

សុន ៖ បាទ! លេខហៅក្នុងតេអូលេង ដល់ចឹងគេហៅគាត់អីចឹង ០៦ ០៥ ។

ដានី ៖ ០៥តាសារឿន?

សុន ៖ តាសារឿន សុទ្ធតែពួកម៉ាក់គាត់ គ្នាគាត់ តាសារឿន០៥ ។

ដានី ៖ ចឹងដល់ពេលកាលជំនាន់នឹង គេដូចថាគេប្រើយើង គេបញ្ជាយើងឲ្យ ឧបមាថាយើងគេចង់ចាប់ក្នុងក្រុមរបស់ពូ ដូចថាខាងលើៗពូចឹង គេមកប្រាប់យើង ថាត្រូវចាប់ត្រូវអីចឹងចទៅ?

សុន :	គេចាប់អីកម្លាំងណាដែលទុកចិត្តគេហៅទៅជួប ទៅប្រាប់ ។

ដានី :	គេទៅប្រាប់?

សុន :	បាទ! ដែលកម្លាំងណាដែលគេទុកថា មិនល្អគេមិនឲ្យដឹងទេ ។

ដានី :	គេប្រាប់នឹង គេមកប្រាប់ថានឹងខុសអីៗ?

សុន :	ខុសអី ក្បត់អីចឹងវាទៅធ្វើសកម្មភាពអីចឹង ដូចខ្ញុំនិយាយមិញចឹងអានឹងហើយគេហៅសកម្ម ភាពនោះ ។ ហើយឧទាហរណ៍ថាយើងដើរទៅធ្វើការស្អីចឹងទៅ យើញដូចថាដានស្អីៗយើង យើញថាដានយួនដានអីចឹងចូល ចេះនិយាយដូចថាបំភ័យយុត្តិសាស្ត្រអីចឹង អានឹងក៏គេចោទយើង ។

ដានី :	ហើយមួយទៀត បើតាមពូមានប្រសាសន៍មិញ ដូចថាកាលនឹងគ្រាន់តែមានកំហុសផ្ទាល់ខ្លួន ពូដែលមានឲ្យយោបល់ថា គាត់មិនមែនក្បត់អីចឹង ដោយសារបញ្ហា?

សុន :	យើងមិនហ៊ាន ។

ដានី :	អត់ហ៊ាន?

សុន :	បាទ! មិនហ៊ាន ។

ដានី :	គេបញ្ជាមកយើងធ្វើតាមចឹង?

សុន :	បាទ! គ្រាន់តែខ្ញុំដូចរ៉េតដូចអីនឹងទៅ គេហៅខ្ញុំទៅ គ្រាន់គេប្រាប់ៗថា«ឯងយើញទេ នៅជាមួយគ្នា ដឹងដែលសកម្មភាព ។ ហ៉! ដើរធ្វើការព្រំដែនមិនដឹងជាស្អីៗ យួនចូលក៏មិនដឹង យួនចូលមកដាក់មីនក៏មិនដឹង ហើយឲ្យទៅតាមយួនហើយគ្មានការប្រុងប្រយ័ត្នជាមុន អានឹងហើយសកម្មភាពក្បត់» គេនិយាយថាចឹង ។ ដល់ចឹងអានឹងហើយគេចាប់ ។

ដានី :	ពូអ្នកចាប់ដែរអត់?

សុន :	បាទ! ខ្ញុំមិនមែនអ្នកចាប់ទេ គ្រាន់តែនាំទៅឲ្យកន្លែងគេចាប់ ។ អ្នកចាប់នឹង សូម្បីតែអ្នកចាប់នឹងយើងមិនដឹងថាអ្នកណាទេចាប់ ។ ប៉ុនគ្រាន់យើងមានទិសដៅមួយ គេឲ្យនាំដាក់ចំនុច ណា យើងនាំដាក់ត្រង់នឹង ។

ដានី :	តែអ្នកដែលដូចឈ្មោះរ៉េតអី គេដឹងថាពូអ្នកនាំឲ្យគេទៅ?

សុន :	ខ្ញុំអ្នកនាំ ខ្ញុំអ្នកនៅជាមួយគ្នាៗធ្លាប់ចឹងនឹង គ្រាន់តែកាំភ្លើងអីយើងដកខ្លួនយើងចឹងមក គេមិននេះទេ គេឲ្យដែរគេមិនប្រឆាំងមិនអីទេ ។

ដានី ៖ គាត់ដឹងខ្លួនមុនដែរ?

សុន ៖ បាទ! គេដឹងថា មិនមែនថានេះទេ គេដឹងថាទៅក្រោយ មិនដឹងថាចាប់ទេ ឧទាហរណ៍ប៉ុនអានឹងគេមាននីតិវិធីគេនិយាយ ។ ឧទាហរណ៍ថាយើងត្រូវទៅក្រោយ ចឹងកម្លាំងត្រូវផ្លាស់ប្តូរនៅការដ្ឋានៗកំពុងសំរុកធ្វើស្រែធ្វើអីចឹង យើងការងារព្រំដែនរយាលចឹង ត្រូវដកកម្មាភិបាលខ្លះ ឬមហាជនខ្លះដើម្បីទៅជួយការងារខាងនោះ ។ តាមពិតអានឹងគេដកទៅនឹង គេចាប់នឹងឯង ។

ដានី ៖ គេធ្វើចិត្តសាស្ត្រយើង?

សុន ៖ បាទ! ប៉ុនគ្រាន់នីតិវិធីគេនិយាយទេ ។

ដានី ៖ តែដឹងថាគេចាប់នឹង គេសម្លាប់នៅណា ឬគេដាក់គុកនៅត្រង់ណាៗ?

សុន ៖ អត់មាននៅដែរឃើញសម្លាប់នឹងទេ ពួកខ្ញុំយកមកបាត់ៗនឹងមកដល់ភ្នំពេញអីមិនដឹង មកអាចបញ្ជូនមកភ្នំពេញ ។

ដានី ៖ ពូដឹងដែរ កាលនឹងគេបញ្ជូនមកភ្នំពេញ?

សុន ៖ បាទ! បញ្ជូនមកភ្នំពេញ គ្រាន់តែអាចដឹងខ្ញុំអាចដឹងយើងវាច្បាស់ហើយ ប៉ុនគ្រាន់ថាអត់មាននៅនឹងទេ មកបញ្ជូន ។

ដានី ៖ ដឹងថាយកមកភ្នំពេញមកកន្លែងណា?

សុន ៖ អត់ដឹងដែរ ខ្ញុំ ប៉ុនគ្រាន់គេថាយកមកភ្នំពេញៗគេដឹកឡានខុបឡានអីចឹង ។

ដានី ៖ បាទ!គេដាក់ឡានខុប?

សុន ៖ ប៉ុនយើងដាក់ត្រង់ណាៗខ្ញុំមិនដឹងទេអានឹង យើងអ្នកទាហាននៅមុខ ។

ដានី ៖ ក្រោយមកទៀតដឹងដែរអត់?

សុន ៖ អត់ ។

ដានី ៖ ចុះតាឈិន តាសយដឹង?

សុន ៖ តាឈិន តាសយ គេចាប់នឹងក៏មិនដឹងថាគេយកទៅណាដែរ ។ បើថាគេចាប់ៗដឹងថាចាប់ប៉ុនមិនដឹងយកទៅណា ។ ដូចថាជំនាន់នោះមិនអាចដឹងគ្នាបាន គ្រាន់តែអ្នកមករៀនចឹងមករៀន៣០នាក់ ទៅវិញដូចថាបានតែ១០នាក់ ឬ៥នាក់អីចឹង ។

ដានី ៖ អត់ដឹងទៅណា?

សុន ៖ អត់ដឹងទៅណា សូម្បីតែគ្នាឯងទៅរៀនជាមួយក៏អត់ដឹងដែរ ប៉ុនគ្រាន់យើងក្នុងចិត្ត យើងដឹងថា តែបាត់ហើយគេចាប់ហើយ យើងដឹងចឹងដែរ ។

ដានី ៖ បើតាមពូប៉ាន់ស្មានមើល កាលជំនាន់តាំងពីយើងទៅតាំងពី៧៥រហូតដល់៧៨ អ្នកដែលគេត្រូវចាប់ទៅអស់ច្រើនអស់ ក្នុងកងពល?

សុន ៖ អឺ! ខ្ញុំភ្លាប់មិនបានទេ បានតែអ្នកនៅជាមួយគ្នា ។ ហើយអ្នកផ្សេងៗដូចថាយើងមិនដែលបានទំនាក់ទំនងគ្នា ចាប់ចងអីប៉ុន្មានអត់ដឹងទេ ។

ដានី ៖ ចុះពេលគាសាន គាត់ចូលទៅកាន់កាប់ដូចថាពូនៅតួនាទីនឹងដដែល?

សុន ៖ ខ្ញុំនៅដដែល ។

ដានី ៖ អត់មានឡើង?

សុន ៖ បាទ! រហូតទល់ខ្ញុំដាច់ជើង ។

ដានី ៖ ចុះពូខស្វាហ៍មកប្រជុំនៅមន្ទីរកងពល យើងឡើងមកប្រជុំធម្មតា?

សុន ៖ មុនដែលខ្ញុំដាច់ជើងនឹង មកប្រជុំធម្មតាដូចថាយើងមានដែនការព្រំដែនធំៗអីចឹងគេហៅទៅព្រោះយើងអ្នកនៅប្រចកព្រំដែន ។

ដានី ៖ បាទ! មកប្រជុំជាមួយ?

សុន ៖ កន្លែងកងពល ។

ដានី ៖ មកប្រជុំ កន្លែងកងពល?

សុន ៖ បាទ!

ដានី ៖ ប្រជុំធម្មតា ។ ហើយចុះគេមានបញ្ចូលដូចថាសមាសភាពថ្មី ពីខាង៨០១ ឬក៏គេរើសថ្មីអីចូលទៅថែមជំនួសកម្លាំងចាស់ដែលគេចាប់ទៅ?

សុន ៖ ដូចអត់មានរើសដង ឧទាហរណ៍ថាមកតាំងពីជំនាន់ឈិនដំបូង គេចាប់អស់ម៉ាជំនាន់នឹង អានឹងគេយកមកចាប់ពីកងវរៈទៅ ។ បាទ!អានឹងគេយកមកពីនឹងទាំងអស់ ។

ដានី ៖ មន្ទីរ៨០១?

សុន ៖ បាទ! ឬក៏អនុសេនាធំខ្លះ អនុសេនាធំឧទាហរណ៍ថាប្រធានក្រុមអីទៅពី៨០១អីចឹង ទៅដល់នោះប្រធាន.......(ខ្យល់) ។

ដានី ៖ តែពូចាស់ ពួកគេមកថ្មីៗ យើងនៅធ្វើការជាមួយគ្នាដែរ ឬក៏ក្នុងស្ថានភាពមួយនៅតែខ្លាចគ្នា នៅតាមដានគ្នា?

សុន ៖ អានឹងគេតាមដានៗយើងតាមដាន ប៉ុន្តែខ្ញុំទស្សនៈនៅនឹង បើនៅព្រំដែនបើថាអ្នក៨០១ទៅនិយាយទៅបើមានចំនុចខ្សោយអីខ្ញុំអត់ខ្លាច ខ្ញុំហ៊ានៗនិយាយត្រង់ៗនិយាយទៅឧទាហរណ៍ថាឡើងនៅសមរភូមិឡើងវៃកំពុងប្រយុទ្ធគ្នាចឹង គាត់មានសិទ្ធិមកពី៨០១ក្តោប

ក្តាប់យើងមែន ប៉ុន្តែដូចថាអត់ឈានមុខយើង អត់ដើរតួជាងយើងៗថាឲ្យវិញ ប៉ុនគេអត់ហ៊ានចាប់យើងដែរ ។

ដានី : គេអត់ហ៊ាន?

សុន : ឧទាហរណ៍ថាយើងមេៗមិនត្រូវទៅមុនដល់ពេលវៃអី មិនត្រូវឡើងទៅមុនកូនទាហាន ដល់ចីនបញ្ជារនៅតែក្រោយចីន ខ្ញុំមានហៅតភាស្តីឲ្យអីចីន អត់អីទេ ។

ដានី : ស្តីឲ្យនៅចំពោះមុខគាត់?

សុន : បាទ! ចំពោះមេ ។

ដានី : ហើយក៏ពេលប្រជុំជាមួយប្រធាន?

សុន : ពេលអាយើងវៃយើងអីនឹង ប៉ុនដល់ពេលប្រជុំជួយមតិគ្នាទៅវិញទៅមក ប៉ុនគេអត់យកកំហុសយើងដែរ ។ ដល់ចីនខ្លះ គេចូលចិត្តវិញ ។

ដានី : តែពួកខាង៨០១ សុទ្ធមកពីខាងណាស្រុកកំណើត?

សុន : ៨០១ចំរុះ ក្រចេះក៏មាន កងវរៈខ្ញុំក្រចេះ នៅបុសលាវ ។

ដានី : នៅបុសលាវ?

សុន : បាទ! ខ្មោចញើសនឹងគាត់ស្លាប់ហើយ ។

ដានី : គាត់ស្លាប់នៅណា?

សុន : ស្លាប់នៅមណ្ឌលគិរីនឹង ។ គាត់អនុធនសិស្សៗ ញើសនឹង អង់ដែនទីអីរលាយអស់ហើយគានឹង គាត់ស្លាប់នឹងជាន់មីន ។

ដានី : ចុះពេលដែល៧/៨អីនឹងវៃជាមួយយួនវៃខ្លាំងៗ ដូចសមរភូមិនៅខាងស្វាយរៀងខាងអី?

សុន : វៃខ្លាំង ។

ដានី : វៃយ៉ាងម៉េចខ្លះ?

សុន : វៃដែល៧/៨ដែលគេចូលហើយថ្ងៃខ្ទង់ថ្ងៃប៉ុន្មាន ថ្ងៃ៣០ខែ១២ ខែ១ វៃៗខ្លាំង ។ តែក្រោយមកដែលវៃចូលទូទាំងប្រទេសម៉ង អានឹងខ្ញុំដាច់ជើងអស់ហើយ ។

ដានី : ពេទ្យ នៅពេទ្យណា?

សុន : ខ្ញុំនៅពេទ្យកងពល នៅមណ្ឌលគិរី នៅកោះញែក ។

ដានី : នៅកោះញែក?

សុន :	បាទ! នៅស្រុកកោះញ៉ែកម៊ង់ មន្ទីរពេទ្យគេ មន្ទីរពេទ្យគេមានពកន្លែងៗ វះកាត់ៗ ហើយ មានមកកន្លែងបំប៉នថែអីចឹង ។

ដានី :	ដាច់ជើងនឹងពូជាន់មីន?

សុន :	ជាន់មីន ។

ដានី :	មីនយើងគ្នាឯង ឬក៏មីនរបស់យួន?

សុន :	អត់ទេ អាមីនរបស់យួនៗដែរដាក់ ។

ដានី :	ដាក់នៅកន្លែងណា?

សុន :	ដាក់នៅព្រំដែន ដាក់នៅតាមបន្ទាយ ដូចថាគេដាក់ការពារបន្ទាយគេចឹង បាទ! យើងឡើងទៅវ៉ៃ ។

ដានី :	នៅម្តុំណាដែលពូ?

សុន :	នៅ ត្រង់នឹងគេហៅផ្លូវលេខ១៨ វាព្រំដែនត្រង់នឹងវាមានផ្លូវជាតិខាន់ព្រំដែន យកផ្លូវមកធ្វើព្រំដែនម្ខាងម្នាក់ ។ ហើយដែលខ្ញុំឡើងទៅ នឹក៏ដោយសារតែពួកខាង៨០១ទៅដែរ ៨០១គេមិនក្តាប់ពីលើខ្ញុំទៀត ។ ដល់ចឹង ប៉ុន្តែទៅប្រជុំទទួលផែនការអី ខ្ញុំទៅដែរ ប៉ុន្តែមនុស្សខ្ញុំចិត្ត ខ្ញុំប្រកែកអត់ឈ្នះគេទេ ខ្ញុំទៅ ។ ចឹងទិសដៅពីវរសេនាធំទៅ អត់ឲ្យទៅវ៉ៃទៅអីទេ ឧទាហរណ៍ថាវ៉ៃឈ្លបវ៉ៃអីអត់ទេ គ្រាន់តែទៅចាក់ចំរូង នឹងទៅយាមថាយួនចេញចូលដីយើងអីឲ្យដឹង ។ តែគេនោះដូចថាសាកចិត្តខ្ញុំ ឬក៏គេចង់ឈ្នះម៉េចទេ របៀបដឹកនាំសិទ្ធិនៅប៉ុនគ្នា ប៉ុនគ្រាន់ថាអត់ទាន់ប្រកាស អត់ទាន់ចាត់តាំងអីចឹង ។ ដល់ចឹងគេរៀបខ្ញុំថាឲ្យទៅវ៉ៃឈ្លប ដល់ចឹងខ្ញុំប្រកែកថា “ចឹងយើងទៅប្រជុំផែនការពីវរៈសេនាធំថាអត់ឲ្យវ៉ៃទេ ថា«ហ៊ើ!ត្រូវតែវ៉ៃ» ។ ចឹងគេយកគេពី៨០១ទៅ ចឹងគេយកឥទ្ធិពលនឹងគ្រប់ដណ្តប់យើង ដល់ចឹងខ្ញុំចិត្ត ខ្ញុំទៅវ៉ៃ ទៅគ្នា៣នាក់ ។

ដានី :	ទៅ៣នាក់?

សុន :	បាទ! គេយកកម្លាំងទៅ៣នាក់ គេប៉ុន្មាននាក់ គេចាក់ចំរូងហើយគេមកផ្ទះមក គេមកកន្លែងមកឲ្យខ្ញុំទៅវ៉ៃ៣នាក់ អត់ទាន់ហូបបាយទេ ។

ដានី :	ទៅវ៉ៃឈ្លប?

សុន :	បាទ! ទៅវ៉ៃឈ្លប ។ ទៅទម្រាំបានវ៉ៃនឹងវង្វេង២-៣សារ វង្វេងនឹងថាមិនឲ្យខ្ញុំទៅវ៉ៃដែរ ប៉ុនវង្វេងៗថាចិត្តខ្ញុំទៅទៀត ។ ៣សារវង្វេង ខ្ញុំឡើងទៅក្រោយឡើងទៅដល់ឃើញផ្លូវទៅ ទៅដល់បន្ទាយនឹងរៀបនឹងវ៉ៃនឹង ខ្ញុំជាន់មីន ជាន់អាបង្កោលឡាក់ព្រំដែន អាបង្កោលគេធំ

បង្គោលផ្ទះដូចថាផ្ទះបារាំងជិនទាន់បារាំងពីដើមនោះ មាននៅថ្មមាននៅអីនោះ ។ ទៅនៅជាន់ៗអាអ្នកដើរខាងៗអែបៗខ្ញុំនេះ មិនថាខ្ញុំជាន់មីនទេ ថាយួនបាញ់ចុះភ្នែកនៅមើលតែយួននោះ យួននៅនិយាយ ឮដល់វានៅសម្រាកព្រំនេះឃើញដំបូងវាហើយនោះ ។ ដល់ចឹងរៀបបាញ់ហើយខ្ញុំជាន់ ពួកនឹងថាយួនបាញ់ខ្ញុំរត់ចោលអស់ទៅ រត់ទៅក្រាបឆ្ងាយដល់ខ្ញុំងើបឡើង ខ្ញុំដឹងខ្ញុំត្រូវមីនស្រែកហៅគេនឹង បានអាមួយរត់មកអាមួយទៀតរត់បាត់ ទៅបណ្ដោយ ។ រត់ដឹងមកងងឹតទាំងអស់ ខ្ញុំថាយួនបាញ់ខ្ញុំកាំភ្លើងយើងខ្សៀកបាត់អស់ ហើយខ្ញុំស្មាងទៅ ខ្ញុំស្ទាបថាខ្ញុំជាន់មីនខ្ញុំស្ទាបរាវរកកាំភ្លើងអីបាត់ទៅ ឃើញរណ្ដៅមីននៅ ក្រោមខ្លួនខ្ញុំដឹងថាជាន់មីនទាញបង់ទាញអីពីហោប៉ៅ ខ្ញុំទាញអាបង់នឹងរុំជើងអីនឹងហើយ ខ្ញុំហៅគេមកៗដល់បានគេរត់មកខ្ញុំនឹងអូសៗ អាម្នាក់នឹងតូចជាងខ្ញុំមានអូសមិនរួចដងនឹងគ្រាន់តែគ្រាននឹងដូចភ័យផងអីផង ញ័រគ្រាខ្ញុំអត់រួចទេ ។ ខ្ញុំថា“មិនបាច់គ្រាទេ ឲ្យអូសៗគ្រាន់តែអូសដល់ជើងភ្នំ ប្រហែល១០០ចូលដល់ក្នុងព្រៃ យួនមកដល់កន្លែងខ្ញុំផ្ទុះនឹង ។មកដល់វាឈរ ខ្ញុំនៅដេកចឹង ដេកមើលទៅលើមកឈរគ្នា៤-៥នាក់ ។

ដានី : តែវាអត់ឃើញពូទេ?

សុន : វាឃើញដែរ វានិយាយញ៉ុងញ៉ាំង វាឃើញឈាមដែលគេអូសខ្ញុំទៅ ឈាមតាមស្មៅចឹងទៅនឹងរហូត ហើយស្មៅដាមប៉ុននេះ អាស្មៅត្រឹមៗនេះ ឃើញដានចឹងទៅវាចង្អុរទៅព្រៃហើយខ្ញុំដេកមើលម្នាក់ទៀត ឲ្យទៅហៅអាម្នាក់ដែលរត់ចោល ហៅតាមសែងខ្ញុំ ។ដល់ចឹង វានិយាយញ៉ុងញ៉ាំងៗយូរចឹង វាបាញ់អ៊ឹមទៅពីលើខ្ញុំបុកដើមឈើលើនឹងបាញ់មកលើខ្ញុំ ២គ្រាប់ បាញ់ចឹងទៅវាអត់ហ៊ានតាម វាទៅបន្ទាយវិញៗ ។ពួកនឹងយកស្នែងយកអីចង សែងខ្ញុំទៅ ចងសែងទម្រាំដល់កន្លែងឈប់៣-៤ដងឆ្ងាយដែរ ។ មកដល់កន្លែងពេទ្យម៉ា យប់វាស់ភ្លឺបានដល់ពេទ្យជាន់តាំងពីម៉ោង៣ថ្ងៃៗ ទាល់តែម៉ាយប់វាស់ភ្លឺឡើងដល់ព្រឹក ម៉ោង៧-៨បានដល់ពេទ្យ ។

ដានី : ចុះឈាមហូរ?

សុន : បាទ! ហូរឡើងអស់ហើយ ហូរបើថាខ្ញុំនៅប្រហែលជាកន្លះគីឡូ ម៉ាគីឡូទៀតបានដល់ពេទ្យក៏ងាប់ដែរ ខ្ញុំសន្លប់ដុំៗហើយនោះ ។ ហើយសែងនោះ សែងកាត់ភ្លៀងទៀត ភ្លៀងម៉ាយប់វាស់ភ្លឺ សែងគ្នាដូចថាវាស៊ូដែរ ។

ដានី ៖ ខែប៉ុន្មាន ៧៨?

សុន ៖ ខ្ញុំខែ៥ ។

ដានី ៖ ខែ៥ ៧៨?

សុន ៖ ខែ៥ ៧៨នឹងស្រុកនឹងវាភ្លៀងហើយ ភ្លៀងជាប់ ។

ដានី ៖ ពូដេកពេទ្យនឹងដល់បែកៗ៧៩?

សុន ៖ បាទ! ដល់បែកខ្ញុំដេករបួតៗ មិនទាន់ជាទេ ខ្ញុំរត់នឹងនៅខ្ទះនៅឡើយ បេះរត់តាមគេច្រត់

ដានី ៖ ចុះរត់ម៉េចទៅដល់ពេលពូ?

សុន ៖ យើងដើរឈើច្រត់ខ្ទះចឹងទៅ មានក្របីជិះក្របីខ្ទះទៅ រទេះគោអីបើអស់ទៅយើងដើរច្រត់ ចឹង ប៉ុនលែងគិតអីកាលនឹង វាផាប់ក៏ផាប់ទៅ បេះតែរស់ទៅ បេះដើរតាមគេទៅ ។

ដានី ៖ ដើរមកជាមួយកងពលទាំងអស់គ្នា?

សុន ៖ បាទ! ដើរអ្នកដើងជាៗនឹងដើរគេជួយយើងខ្ទះយកអីវ៉ាន់អីខ្ទះ ដើរដើង ។

ដានី ៖ ចឹងពេលយួនចូលមកដំបូង ពូរត់មកខាងណា ជំនៀរខាងណានៅកោះញែក?

សុន ៖ និយាយទៅនៅ៣ខែនឹង រត់វិលនឹងក្រចេះ ស្ទឹងត្រែ មណ្ឌលគិរី រតនគិរីនឹង ។

ដានី ៖ ចឹងវិលនឹង?

សុន ៖ បាទ! វិលនៅនឹង ។

ដានី ៖ ប៉ុលពតក៏វិលនឹង?

សុន ៖ បាទ! ជួនណាឆ្ងាយទៅរតនគិរី ជួនណាស្ទឹងត្រែង ពីក្រោយស្ទឹងត្រែង អូរពងមាន់ ។

ដានី ៖ អឺ! វិលនឹងរហូតដល់ពេលណាបានយើងមក ចេញពីជុត?

សុន ៖ ខ្ញុំនោះ ឡើងភ្នំមកដងរែក មកនៅដើងនឹង ខ្ញុំមកនៅ៨២ ។

ដានី ៖ ៨២?

សុន ៖ ១៩៨២ ប្រហែលជាខែប៉ុន្មាន ខែ១ ខែ២ ខែប្រាំង បើមិនខែ១១ ខែ១២នឹង ខែរាំង ស្រក់ទឹកហើយបានខ្ញុំឡើង ។ បានមកភ្នំដងរែក ។

ដានី ៖ ចឹងកងពលទាំងអស់ ដល់ពេលឆ្នាំ៨២បានយើងចេញជុតពី អ្នកឡើងភ្នំនឹង?

សុន ៖ បាទ!

ដានី ៖ ចឹងនៅចន្លោះពី៧៩ ៨០នឹង ពូនៅជាមួយកងពលដដែល?

សុន ៖ អត់ទេ និយាយថាកងពល តាំងពីខ្ញុំដាច់ដើងមក វាដូចថាដាច់អាណត្តិហើយ មកនៅក្រសួងមន្ទីរ នៅមន្ទីរពេទ្យមន្ទីរអីនឹង នៅកន្លែងអ្នកពិការគេច្រើនឲ្យនៅតាមក្រសួងមន្ទីរ

ពេទ្យនៅតាមកន្លែងកងពលនឹង លែងមានអីនៅហើយ យើងដាច់ពីទាហានហើយនឹង ។ ដល់ចឹងកាលខ្ញុំនោះនៅបណ្ដោះអាសន្នសិន នៅកន្លែងពេទ្យនោះ ប៉ុនដល់រត់លូនចេះរត់ជាមួយគេជាមួយឯងមក ។

ដានី : ដល់ពេលឡើងភ្នំទៅ ពូមកនៅណាទៅ?

សុន : ឡើងភ្នំខ្ញុំនៅមន្ទីរតាខៀវនេះ ។

ដានី : មន្ទីរតាខៀវ?

សុន : បាទ! នៅក្រសួងមន្ទីរ ខ្ញុំនៅឃ្លាំងមកឡើងលើភ្នំ ខ្ញុំនៅឃ្លាំង ។

ដានី : ហ្នឹងនៅមន្ទីរជាមួយសុន សេន?

សុន : បាទ! នៅជាមួយតាខៀវ ជាមួយសុន សេន ។

ដានី : នៅកន្លែងនឹងខ្លះ?

សុន : នៅភ្នំដងរែក នៅខាងជើងនៅទន្លេល្ពៅ គេហៅទន្លេល្ពៅ ។

ដានី : ខាងទន្លេល្ពៅ ខាងព្រំដែន?

សុន : បាទ! អានឹងមុំពាកន្លែងលាវផង ខ្មែរផង ថៃផងនឹង នៅនឹង ។

ដានី : គ្នាច្រើនទេនៅនឹង?

សុន : ច្រើនណាស់ មិនតិចទេ គ្នាវារាប់កងពលចំរុះ ដឹងខាងណាខាងណៃ មានតាំងពីភូមិភាគកណ្ដាល មានតាំងពីកងពល មិនដឹងពីណាណៃច្រើនណាស់ ។

ដានី : តាអាន គាត់នៅនឹងដែរ?

សុន : អឹំអាន នៅនឹងដែរ គាត់ប្រធានភូមិនៅនឹង ។

ដានី : នៅណា?

សុន : នៅនឹងកន្លែងទន្លេល្ពៅ ។

ដានី : ទន្លេល្ពៅ?

សុន : គាត់ខាងប្រជាជនលើគាត់ ។

ដានី : ប្រជាជនទាំងអស់?

សុន : បាទ! ទាំងអស់ ។

ដានី : គាត់មក កាលរត់នឹង គាត់មកពីភូមិភាគកណ្ដាល?

សុន : ខ្ញុំមិនដឹងច្បាស់ដែរ គាត់នឹងបែបនៅភូមិភាគកណ្ដាលមុន ឡើងមកលើភ្នំគេឲ្យគាត់ក្ដាប់ខាងប្រជាជន ។

ដានី ៖ ខាងក្តាប់ប្រជាជន?

សុន ៖ បាទ!

ដានី ៖ នៅកន្លែងមុំ៣នឹង?

សុន ៖ បាទ!

ដានី ៖ ប្រជាជនច្រើនកាលនឹង?

សុន ៖ ប្រជាជនច្រើន បើនិយាយពីភូមិ បើនិយាយពីឃុំ បែបស្មើនឹងឃុំនេះ ច្រើនដែរនឹងម៉ាភូមិ គាត់កាលនឹង ។

ដានី ៖ កាលនឹងនៅនឹងចំរុះ ដូចពូមកពីខាងកំពង់ចាម?

សុន ៖ ចំរុះ និយាយពីស្រុកភូមិយើងវាមានចំរុះ វាមានកំពង់ធំ កំពង់ចាម តាកែវ កំពត ព្រៃវែងមានទាំងអស់ ។

ដានី ៖ មីងកាលនឹងនៅនឹងដែរ? ចុះពូជួបមីងឆ្នាំណា?

សុន ៖ ខ្ញុំរៀបឆ្នាំ៨៧ ។

ដានី ៖ ឆ្នាំ៨៧?

សុន ៖ បាទ! ខ្ញុំនៅក្នុងដីថៃ ។

ដានី ៖ ចឹងកាលពូនៅទន្លេល្ពៅខាងមុំ៣ កាលនឹងពូជួបមីងនៅ ស្គាល់មីងនៅ?

សុន ៖ បាទ! ស្គាល់គាត់នឹង គាត់ស្គាល់តាំងពីខ្ញុំដេកពេទ្យ ។

ដានី ៖ អូ! កាលនឹងមីងនៅមណ្ឌលគិរីដែរ?

ប្រពន្ធ ៖ ចាំ! ខ្ញុំនៅពេទ្យកងពល ។

ដានី ៖ ពេទ្យកងពល ។ មីងគាត់ទៅតាំងពីជំនាន់៧៥ជាមួយគ្នា?

សុន ៖ ជំនាន់នឹង ម៉ាជំនាន់នឹងឯង ។

ដានី ៖ ចុះតាអានគាត់អ្នកស្រុកកំណើតណាដែរ?

សុន ៖ ខ្ញុំអត់ស្គាល់ច្បាស់ទេ អ៊ំអាន គាត់នៅខាងណា ខាងតាកែវ ខាងកំពតមិនដឹង តាកែវ មិនដឹង ។

ប្រពន្ធ ៖ បងមីងរីន អ៊ំអាន មីងរីន ប្រពន្ធបង០៦នៅនេះឯង ។

ដានី ៖ បង?

ប្រពន្ធ ៖ បងមីងវិញ ប្រពន្ធបង០៦ តាសាន ។ គាត់មកនៅនេះដែរ ។

សុន ៖ បងគាត់បង្កើត បងមីងរីនបង្កើត មីងរីននឹងត្រូវប្រពន្ធតាសាននឹង ។

ដានី :	តាសានគាត់ស្លាប់បាត់ហើយនឹង?

សុន :	បាទ! គាត់ស្លាប់ ។ គាត់នៅនេះសព្វថ្ងៃ ។

ដានី :	ចឹងពូទៅនៅមុំពានឹងរហូតដល់ពេលណាបានផ្លាស់?

សុន :	ខ្ញុំនៅយូរដែរ នៅទាល់តែឆ្នាំ មើល៩១ខ្ញុំចុះមកនៅអន្លង់វែង ។

ដានី :	ឆ្នាំ៩១ចុះមកនៅអន្លង់វែង?

សុន :	បាទ! នៅអន្លង់វែងបានម៉ាឆ្នាំ ។

ដានី :	ចុះមកទាំងអស់គ្នា?

សុន :	បាទ! ចុះមកទាំងអស់គ្នា ក្រសួងមន្ទីរតាគៀវមកនៅនឹងទាំងអស់ អន្លង់វែង ។ ដល់ឆ្នាំ៩២មកនៅនេះ ។

ដានី :	ចុះពូមានប្រសាសន៍មិញថា ពូរៀបការឆ្នាំ៨៧?

សុន :	បាទ!

ដានី :	៨៧នៅដីថៃ?

សុន :	៨៧ បាទ!កាលនឹង ។

ដានី :	យ៉ាងម៉េចដូចថាកាលនឹងពូមានប្រសាសន៍ថាពូនៅកន្លែងមុំពារហូតដល់៩១បាន?

សុន :	មុំពានឹង ប៉ុន្តែកន្លែងដែលស្នាក់នៅនឹង យើងនៅលើដីថៃទេ ។

ដានី :	អូ! ចឹង?

សុន :	បាទ! នៅលើដីថៃទេ ដែលថៃគេឲ្យនៅតាមក្បែរៗនឹង ។ មិនមែននៅលើដីយើងទេៗ ទាហានធ្វើការបាញ់ដល់នឹង ។ ប៉ុននៅលើដីថៃ ឃ្លាំងកន្លែងទប់សម្ភារៈនៅលើដីថៃទេ មកដឹកមក ។

ដានី :	យកសម្ភារៈ ។ ចឹងដូចនៅនឹងពូអ្នកកាន់ឃ្លាំង?

សុន :	បាទ! ខ្ញុំអ្នកសម្រាប់បើកបរឲ្យគេ ដែលពេលនឹងទ័ពគេអីចឹងមកបើក ខ្ញុំមកបើកសម្ភារៈ ។

ដានី :	សម្ភារៈ?

សុន :	បាទ! សម្ភារៈដូចជាខោអាវ គ្រាប់រំសេវអីនឹង សម្ភារៈប្រើប្រាស់ ។

ដានី :	ដល់ពេលឆ្នាំ៨៧បានរៀបការជាមួយមីង ។ រៀបការយ៉ាងម៉េច យើងបានរៀបការតាមប្រពៃណី?

សុន :	យី! វាគ្មានទេ ជំនាន់នោះ យើងការ២-៣គូ ។

ដានី :	២-៣គូ ចាប់ដៃចឹងដែរ?

សុន ៖ បាទ! ការនៅជំនាន់នឹង ។

ដានី ៖ កាលនឹងដូចថាយើងពូពេញចិត្តទៅវិញទៅមក ឬក៏?

សុន ៖ គ្មានអ្នកណាបង្ខំ ។

ដានី ៖ ខាងអ៊ំៗតាៗគាត់រៀបចាត់ចែងឲ្យ?

សុន ៖ អត់ៗមានអ្នកណាបង្ខំ ពេញចិត្តខ្លួនយើង ។

ដានី ៖ មិនមែនតាអាន គាត់អ្នករៀបចំ?

សុន ៖ បាទ! និយាយទៅកាលនឹងគេបង្ខំ ទាល់តែយើងស្រឡាញ់យើងនេះដែរ ក្រោយមកបើយើងមិនស្រឡាញ់ មិនព្រមព្រៀងគេក៏មិនបង្ខំ ។

ដានី ៖ អូ! ព្រមព្រៀង កាលនឹងរៀបការប៉ុន្មានគូដែរ?

សុន ៖ ការខ្ញុំ៣គូ ។

ដានី ៖ ៣គូ?

សុន ៖ បាទ!

ដានី ៖ ចុះមីងៗកាលនឹងធ្វើអី កាលនៅមុំ៣?

ប្រពន្ធ ៖ ខ្ញុំនៅឃ្លាំង ។

ដានី ៖ នៅឃ្លាំងជាមួយពូដែរ?

ប្រពន្ធ ៖ អត់ទេ ខ្ញុំនៅឃ្លាំងផ្សេង ឃ្លាំងគ្រាប់ ។

ដានី ៖ តែយើងនៅឃ្លាំងអីចឹង យើងនៅខាងស្រុកក្រោយ មិនមែនទាហាន ខាងប្រជាជនតើអានឹង?

សុន ៖ មិនមែនទាហានទេ នៅក្រោយ ។

ដានី ៖ គេហៅប្រជាជនអានឹង?

សុន ៖ បាទ! យើងនៅឃ្លាំង កន្លែងឃ្លាំង យើងនៅសម្រាប់ថែទាំឃ្លាំង មើលសម្ភារៈបើកបរឲ្យគេនឹង ពេលសម្ភារៈទឹកចូលអី យើងជញ្ជូនចូលឃ្លាំងចូលអីទៅ ។

ដានី ៖ កាលនឹងប្រជាជនយ៉ាងម៉េច ប្រជាជនបានន័យថាកូនៗប្រពន្ធកូនចៅរបស់កងទ័ព?

សុន ៖ ប្រជាជនៗនឹងកូនចៅកងទ័ពនឹង ខ្លះក៏ប្រជាជនសុទ្ធសាធចឹងទៅ ឡើងមកពីក្នុងពីអីជាមួយអ៊ំអានអីអ៊ំអី ខ្លះកូនចៅទ័ព ។

ដានី ៖ ចឹង?

សុន ៖ ប្រពន្ធទាហាន ។

ដានី ៖ ចឹងតាអាន អ្នកមកជាមួយគាត់ច្រើនដែរ?

សុន ៖ បាទ!

ដានី ៖ ដល់ពេលឆ្នាំ៩១បានត្រឡប់មកនៅអន្លង់វែង?

សុន ៖ មក ។

ដានី ៖ ម៉េចបានត្រឡប់ទៅនៅអន្លង់វែង?

សុន ៖ អន្លង់វែងកាលនឹងតាម៉ុកគេដឹកមកនៅនឹង មុនដំបូងថានៅនឹង ដល់ពេលក្រោយមកតាខៀវ គាត់មកនៅគាត់យកមកតាមមកនៅនេះ ក្រសួងមន្ទីរគាត់បញ្ជូនមកនៅនេះទាំងអស់ ។

ដានី ៖ ទៅនៅអន្លង់វែងបានម៉ាឆ្នាំ?

សុន ៖ បានម៉ាឆ្នាំ ។

ដានី ៖ ឆ្នាំ៩១ ដល់៩២ខែប៉ុន្មានបានមកនេះ?

សុន ៖ ៩២ មកនេះខែ២ ។

ដានី ៖ ខែ២?

សុន ៖ ខែ២ ៩២ ។

ដានី ៖ ខែ២ ៩២ ។ ចុះពីខាងមុំពនឹង ពី៩១ខែប៉ុន្មាន?

សុន ៖ ខ្ញុំអត់ចាំទេ អត់ចាំខែទេមើលទៅ ។

ដានី ៖ ចុះមកអន្លង់វែង នៅជុំគ្នា នៅជុំគ្នា?

សុន ៖ នៅជុំៗគ្នា ពួកខ្ញុំនៅម្តុំឃ្លាំងនឹងនៅជុំគ្នា ប៉ុនយើងមានរបៀបផ្ទះចឹងដែរ ប៉ុននៅម៉ាជុំគ្នា ។

ដានី ៖ ម៉ាជុំគ្នា កាលនឹងតាខៀវគាត់អត់នៅនឹងទេ?

សុន ៖ តាខៀវ គាត់មិននៅនឹងទេ គាត់នៅ អឺ!កន្លែងគាត់ថាទៅពិបាកកំណត់គាត់ដើរថានេះតិច នោះតិច គាត់ដើរធ្វើការកន្លែងផ្ទះគាត់ ជួនណាគាត់នៅថៃផង ជួនណាគាត់មកឯលិចនឹង មក ។

ដានី ៖ ដល់ពេលនេះចឹងទៅ គាត់ក៏ឲ្យដឹកមកទាំងអស់មក?

សុន ៖ បាទ!

ដានី ៖ ប៉ុន្មានទៅកាលមកជំនាន់ពួ ពីឆ្នាំ៩២ចាប់ពី?

សុន ៖ អឺ! ខ្ញុំក្តាប់មិនបាន ប៉ុនច្រើន ប្រហែលដឹកប្រហែលជា៣០-៤០ឡានបានអស់ ។

ដានី ៖ ៣០-៤០ឡាន?

សុន ៖ បាទ! ថៃផង ឡាវខ្មែរផង ។

ដានី ៖ ម៉ាឡាវប៉ុន្មាននាក់ ម៉ាឡាវ?

សុន ៖ ម៉ាឡាវជិះបាន១០-២០នាក់អីនឹង សម្ភារៈផងអីផង ។ ច្រើននិយាយទៅប៉ុន្មានភូមិទេ សុទ្ធតែក្រសួងមន្ទីរគាត់ ។

ដានី ៖ ប្រហែលជាប៉ុន្មានភូមិនឹង?

សុន ៖ បាទ! ៤-៥ភូមិ ។

ដានី ៖ ប៉ុន្តែអ្នកដែលប្រជាជននឹង តាអានទេ គាត់អ្នកគ្រប់គ្រង មកដំបូង?

សុន ៖ បាទ!

ដានី ៖ តាខៀវ គាត់អត់នេះទេ?

ប្រពន្ធ ៖ ប្រជាជននឹងតាអានផ្សេង តាអានគ្រប់គ្រងប្រជាជនផ្សេង ។

សុន ៖ តាអាន ក្រសួងមន្ទីរតាខៀវនេះផ្សេង អត់មានតាអានគ្រប់គ្រងទេ ដល់ក្រសួងមន្ទីរនឹង ផ្សេង តាអានផ្សេង ។

ដានី ៖ តាអានផ្សេងម៉េច?

សុន ៖ តាអានខាងប្រជាជនផ្សេងទេ គាត់ទើបមកនេះ គាត់មកក្រោយខ្ញុំទេ គាត់មកនៅនេះ ។

ដានី ៖ គាត់មកនៅកំរៀងនេះ?

សុន ៖ បាទ! ក្រោយខ្ញុំទេ ។

ដានី ៖ ចឹងពីមកឆ្នាំ៩២?

សុន ៖ បាទ! ៩២ ដឹងគាត់មកក្រោយ ប៉ុនមិនដឹងឆ្នាំណា ខ្ញុំអត់ចាំខែប៉ុន្មាន ដឹងគាត់មកក្រោយ ពួកខ្ញុំ ។

ដានី ៖ ក្រោយយូរ?

សុន ៖ បាទ! ក្រោយយូរដែរ ។

ដានី ៖ បាទ! គាត់មកពេលសមាហរណកម្មហើយ?

សុន ៖ អឺ ដូចមិនច្បាស់ទេ ដូចមុន ដូចក្រោយសមាហរណកម្មមិនដឹង ក្រោយ ។

ដានី ៖ ពួមកតាំងពីឆ្នាំ៩២?

សុន ៖ បាទ!

ដានី ៖ ចុះពួមក មកដំបូងដូចថាយើងមកនឹងដំបូងយើងធ្វើអីទៅ យើងប្រជាពលរដ្ឋធម្មតា ឬក៏ យើងធ្វើជាកងទ័ព ឬក៏យ៉ាងម៉េច កាលពីឆ្នាំ៩២?

សុន ៖ មានកងទ័ពប្រជាពលរដ្ឋធម្មតា រកស៊ីចឹងធ្វើស្រែធ្វើចំការ ។

ដានី ៖ ឈប់ យើងឈប់ធ្វើកងទ័ពធ្វើអីហើយ?

សុន ៖ បាទ! ឈប់ធ្វើ ។

ដានី ៖ កាលនឹងពូមានកូនចៅនៅ?

សុន ៖ មានហើយ ខ្ញុំមានកូនប៉ុននឹង ។

ដានី ៖ ៣នឹងហើយ?

សុន ៖ បាទ! ៣នឹង ។

ដានី ៖ ក្រោយមកលែងមានទៀត?

សុន ៖ បាទ!

ដានី ៖ ចឹងចុះចាប់ពីឆ្នាំ៩២មក ដំបូងកន្លែងនឹងសុទ្ធតែព្រៃអីចឹងតើ?

សុន ៖ បាទ! សុទ្ធតែព្រៃ ។

ដានី ៖ ចុះយើងធ្វើ ដូចថាកាលនោះយើងនៅមានរបប យើងនៅមានអី ឬក៏យើងចាប់ផ្តើមរកខ្លួន ឯង យើងធ្វើស្រែចំការខ្លួនឯងហើយ ឬក៏យ៉ាងម៉េច?

សុន ៖ បាទ! អត់មានរបបអីបើកទៀតទេ សមាហរណកម្មនឹងហើយគឺយើងអត់មានរបបបើក ធ្វើស្រែធ្វើអីហូបខ្លួនឯង ។

ដានី ៖ បាទ! ពី៩២ដំបូងមិនទាន់សមាហរណកម្ម?

សុន ៖ បាទ!មុន៩២នឹងអត់ទាន់សមាហរណកម្មទេ អានឹងរបររបស់អីយើងនៅបើកខ្លះ ។ ក្រោយ មកយើងរកហូបខ្លួនយើង ។

ដានី ៖ កាលនឹងសុទ្ធតែព្រៃសុទ្ធតែអី យើងធ្វើម៉េចទៅ យើងដើម្បី?

សុន ៖ យើងកាប់ យើងឆ្ការទៅ រុករានទៅ ។

ដានី ៖ យើងកាប់ យើងធ្វើស្រែ ។ កាលនឹងដូចនៅម្តុំនឹងអីមានមីនមានអីអត់?

សុន ៖ អត់មានទេ តាមនេះ អត់មានៗទេខាងឆ្ងាយៗ នៅម្តុំខ្ញុំត្រង់នេះអត់មាន ។

ដានី ៖ ចឹងស្រួលដែរ បើអត់សូវមានមីនចឹងយើងកាប់អត់សូវខ្លាច?

សុន ៖ បាទ! យើងកាប់ចំការកាប់ ប៉ុនយើងចេះប្រយ័ត្នដែរនឹង កាប់ចេះមើលចេះអីទៅ ។

ដានី ៖ ចុះពូយើងចំការដល់ពូសព្វថ្ងៃ សុទ្ធតែពូកាប់ខ្លួនឯងទាំងអស់?

សុន ៖ កាប់ខ្លួនឯង ។

ដានី ៖ គេអត់ហាមឃាត់យើង យើងកាប់បានប៉ុន្មាន យកប៉ុននឹងទៅ ឬក៏?

សុន ៖ អត់ទេ គេចែកៗ

ដានី ៖ គេចែកៗ?

សុន ៖ បាទ! គេចែកកាប់ចឹងចែកគ្នាទៅ យើងវាស់ម៉ែត្រចែកគ្នា ដីចំការប៉ុន្មាន ដីផ្ទះប៉ុន្មានបាន ចេះចាប់បានៗ ក្រោយៗគេមក ខ្ញុំបានខ្លះ យើងទិញដីថែមទៅឲ្យខ្លះលក់ដីគ្មានយើងទិញ ដីគេថែមៗ

ដានី ៖ យើងទិញថែមទៀតទៅ បើឥឡូវពូបានប៉ុន្មានដែរ ដីសរុប?

សុន ៖ ដីខ្ញុំប្រហែលជា៣០-៤០រ៉ៃៗ

ដានី ៖ ៣០-៤០រ៉ៃ?

សុន ៖ បាទ!

ដានី ៖ ជិតៗនឹងដែរ ឬក៏ឆ្ងាយ?

សុន ៖ ឆ្ងាយដែរ ខាងនោះអូរ ឆ្ងាយទៅលំផាត់ៗ

ដានី ៖ ខាងភូមិលំផាត?

សុន ៖ បាទ! ខាងលំផាត ភូមិលំផាតៗ

ដានី ៖ ខាងភូមិលំផាតឆ្ងាយជាងអូរគគីរ?

សុន ៖ ឆ្ងាយ ហួសអូរគគីរទៅៗ

ដានី ៖ ជិតភូមិគេផ្សេងទៀត?

សុន ៖ បាទ! ចាប់ពីមានអូរមួយហួសបន្ទាយទៅ មាន....(ខ្យល់) ៗ

ដានី ៖ ពូធ្វើតែស្រែចំការ អត់មានរកអីផ្សេងទៀតទេ?

សុន ៖ បាទ! ធ្វើតែស្រែចំការ ចិញ្ចឹមមាន់ ចិញ្ចឹមទា ជ្រូកៗ

ដានី ៖ ចុះនៅដូចថាពូមកដំបូងអី ខាងនេះចាញ់ទេ មានជម្ងឺគ្រុនចាញ់?

សុន ៖ ចាញ់គ្រុនធម្មតា ប៉ុនយើងមានថ្នាំមានអីលេបទៅៗ

ដានី ៖ ថ្នាំអីគេ ថ្នាំបារាំង ឬក៏ថ្នាំបូរាណ?

សុន ៖ មានមន្ទីរពេទ្យគេ ចាញ់យើងទៅមន្ទីរពេទ្យ បើជំនាន់មិនទាន់សមាហរណកម្មក៏មានមន្ទីរពេទ្យៗ

ដានី ៖ មិនមែនប្រើថ្នាំបូរាណ?

សុន ៖ មិនមានប្រើថ្នាំផ្ដេចផ្ដាស់ទេ ថ្នាំល្អៗ

ដានី ៖ ដូចតាអានថាគាត់មានលក់ថ្នាំបូរាណ គាត់មានថ្នាំអីខ្លះទៅ?

សុន ៖ ថ្នាំគាត់ អឺ!ថ្នាំច្រើនមុខដែរ ថ្នាំមើលខាងរោគស្ត្រីក៏មាន ថ្នាំពិស ថ្នាំស្ដីក្រពះ ពោះវៀន អីក៏មានដែរ ។

ដានី ៖ អូ! ចឹង?

សុន ៖ បាទ!

ដានី ៖ គាត់ធ្វើគ្រូបូរាណយូរទេ?

សុន ៖ ទេ! ខ្ញុំពីមុនមកអត់ដឹងគាត់នេះទេ ក្រោយមកដូចថាគាត់ចេះមានរកថ្នាំរកអី ទើបដឹងដែរ ។

ដានី ៖ ទើបដឹងដែរ?

សុន ៖ កាលពីមុនមកៗគាត់មកនៅនេះ គាត់ចេះមានថ្នាំមានអី គេចេះទៅរកៗ អាខ្លះដឹកត្រូវអី ចឹងគេចេះតែរកទៅ ។

ដានី ៖ កាក់កប?

សុន ៖ បាទ! ខ្លះក៏មិនត្រូវៗ ។

ដានី ៖ សព្វថ្ងៃគាត់អត់មានធ្វើស្រែចំការ?

សុន ៖ គាត់ធ្វើដែរ តែកូនចៅគាត់ មានកូនគាត់ជួយ ។ បើគាត់នឹង គាត់ធ្វើលែង គាត់ចាស់ ដែរ ។

ដានី ៖ គាត់ចាស់ហើយ?

សុន ៖ បាទ! គាត់ទៅតែវត្ត ។

ដានី ៖ កាលមកដំបូងគាត់ធ្វើប្រធានភូមិអូរគគីរ?

សុន ៖ អត់ទេ អត់មានធ្វើប្រធានភូមិទេ គាត់ធ្វើប្រជាពលរដ្ឋធម្មតា ។

ដានី ៖ គាត់ប្រជាពលរដ្ឋ ប្រជាជនស្រឡាញ់រាប់អានគាត់ដែរ?

សុន ៖ មិនទេ ។

ដានី ៖ គាត់មនុស្សល្អដែរ?

សុន ៖ បាទ! មនុស្សសាមញ្ញដែរ ។

ដានី ៖ សាមញ្ញ ។ គាត់ធ្វើអាចារ្យវត្ត ឬក៏គាត់ទៅវត្ត?

សុន ៖ អត់អាចារ្យៗក៏គាត់មិនធ្វើ គ្រាន់ទៅសុំសីលសុំទាន ។

ដានី ៖ អូ! គាត់សុំសីល សុំទាន មិនមែនអាចារ្យ ។ វត្តនៅណា?

សុន ៖ វត្តនៅមុខ ទៅហួសនេះតិច ហួសទៅឃើញឃ្លោងទ្វារ ។

ដានី ៖ វត្តគេហៅវត្តអីគេ?

សុន ៖ វត្តអូរដារ ។

ដានី ៖ វត្តអូរដារ?

ប្រពន្ធ ៖ ប៉ាសកដើរវត្តចេញលុយគ្រប់គ្នាកសាង ។

ដានី ៖ ប្រជាជនយើងរៃលុយគ្នាកសាងទៅ អត់មានសប្បុរសជនណាមកពីណា?

ប្រពន្ធ ៖ អត់មានខាងណាជួយទេ អត់មាន កសាងសាលាឆាន់បានមួយហើយ នៅវិហារ ។ ម៉ាឆ្នាំចេះម្នាក់តិចៗ ។

សុន ៖ រំលែកចេះរំលែកកសាង ។

ដានី ៖ ចុះពូបានទៅលេង ដូចថាយើងចេញពីផ្ទះតាំងពីឆ្នាំ៧៣ ដល់ឆ្នាំណាបានពូត្រឡប់ទៅលេងផ្ទះវិញ?

សុន ៖ សមាហរណកម្មហើយ ។

ដានី ៖ សមាហរណកម្ម ហើយ?

សុន ៖ ៩៦ ៩៧ ។

ដានី ៖ ៩៦ ៩៧បានទៅ?

សុន ៖ បាទ!

ដានី ៖ ចឹងបានកាលជំនាន់៣ឆ្នាំអី ពូមិនដែលបានទៅលេង?

សុន ៖ អត់ទេ ។

ដានី ៖ អត់សោះ?

សុន ៖ ខ្ញុំចេញពីផ្ទះអត់បាន ។

ដានី ៖ ចុះកាលជំនាន់នឹង ពូមានដែលធ្លាប់សរសេរសំបុត្រ ឬឮដំណឹងថាពូនៅណា ឬអ្នកស្រុក?

សុន ៖ ធ្លាប់ បាទ! ខ្ញុំធ្លាប់សរសេរ ។

ដានី ៖ ទាក់ទង បានទាក់ទងគ្នាមុន?

សុន ៖ ទាក់ទងដឹងដែរ ខ្ញុំរបួសដាច់ជើងហើយ ខ្ញុំសរសេរសំបុត្រទៅផ្ទះ សរសេរច្រើនដែរ ប៉ុនថា បានដល់សំបុត្រមួយមកដល់ផ្ទះ ។ ឪពុកខ្ញុំបានទទួលដំណឹងថាខ្ញុំដាច់ជើងដាច់អីគាត់ដឹងតើ សរសេរទៅ ។

ដានី ៖ ដល់ពេលពូទៅជំបូងយ៉ាងម៉េចដែរ ពូបែកផ្ទះ ដូចថាតាំងពី៧៣រហូតដល់៩៦ ៩៧ វា ៣០-៤០ឆ្នាំហើយ ដូចថាយើងទៅចេញតាំងពីក្មេង ហើយដល់ពេលពូទៅដូចថារៀង

ចាស់តិចហើយបានពូ បានត្រឡប់ទៅដូចថាយើងទៅដីបូងចឹង បងប្អូន ឪពុកពូគាត់ម៉េចដែរ ឃើញមុខដីបូងឃើញពូ គាត់ស្គាល់មិន ហើយក៏ទាល់តែរំលឹកបានគាត់ស្គាល់?

សុន : អឺ! ចាស់ៗក្មេង អត់ស្គាល់ខ្ញុំទេ ។

ដានី : អត់ស្គាល់?

សុន : បាទ! បើខ្ញុំទៅខ្ញុំបានស្គាល់ចាស់ៗ ខ្ញុំនៅចំណាំបានប៉ុនគ្រាន់ថាកន្លែងភូមិយើងៗទៅមិនដូចដើមទេ វាប្លែកអស់ទៅ ។ បាទ! ដូចភូមិអ្នកដទៃមិនមែនយើងធ្លាប់នៅចឹង ទៅដល់ថ្មីទាំងអស់ ។ យើងអាយើងធ្លាប់ចំណាំអីអត់ដូចមុនទេ ។

ដានី : ចំណាំដើមឈើ?

សុន : បាទ! ខុសអស់ហើយ អត់ចំណាំបានទេ ។

ដានី : មុនដីបូងទៅរកផ្ទះអត់ឃើញដែរ?

សុន : បាទ! ប្រឡំដែរ តែមានគេប្រាប់គេអីចឹងទៅ ។

ដានី : បាទ! ចូលទៅម៉េចដែរ ឪពុកហើយបងប្អូនពូបង្កើត?

សុន : បងប្អូនខ្ញុំនៅ ប៉ុន្តែឪពុកម្តាយខ្ញុំស្លាប់អស់ហើយ ខ្ញុំទៅ ។

ដានី : ពេលទៅនឹង ឪពុកម្តាយស្លាប់អស់ហើយ?

សុន : បាទ! ឪពុកម្តាយខ្ញុំស្លាប់អស់ហើយ ។

ដានី : ចុះបងប្អូនពូគាត់ស្គាល់អត់ដីបូង?

សុន : បងប្អូន គាត់ស្គាល់ ។

ដានី : ម៉េចទៅអារម្មណ៍ពេលដែលយើងជួបគ្នាដីបូង?

សុន : មានអីអារម្មណ៍វា នឹកបែកគ្នា ប្អូនៗខ្ញុំយំហ៊ូ ពេញនឹង ។

ដានី : ចុះមិត្តភ័ក្តិពូ ដូចថាកាលជំនាលវ័យប្រហែលគ្នាកាលនៅស្រុកភូមិ?

សុន : នៅដូចថា នៅភាគតិចណាស់ ដូចថាអ្នកចូលអ្នកអីមក អាខ្លះបាត់អត់ឃើញអត់អីផងទៅផ្ទះបាត់ ប្រហែលជាស្លាប់ ចូលម៉ាសារខ្ញុំនឹងបាត់អស់ច្រើនណាស់ អត់ឃើញទៅស្រុកវិញ ។ បើបាត់មិនឃើញដំណឹង ប្រហែលជាគាត់ស្លាប់ហើយ បើអត់ឃើញទៅ បើនៅរស់ដូចខ្ញុំប្រហែលជាទៅដល់ បាត់ ។

ដានី : ពូទៅស្នាក់នៅផ្ទះបានប៉ុន្មានថ្ងៃ?

សុន : ខ្ញុំទៅ កាលនឹងខ្ញុំទៅនៅចង់កន្លះខែដែរ ។

ដានី : ចង់កន្លះខែដែរ?

សុន : បាទ! ទៅដំបូង ថាខ្ញុំទៅក្រោយមកខ្ញុំទៅម៉ាសារទៀត ខ្ញុំទៅធ្វើបុណ្យ ទៅ២-៣សារ ទៅ ធ្វើបុណ្យម៉ាសារ ក្រោយមកខ្ញុំទៅម៉ាសារទៀត ខ្ញុំទៅលើកខ្មោចឪពុកខ្ញុំ ។ ទៅដំបូងម៉ា សារនឹងលើកអត់បាន គេមើលគ្រូមើលអីថាចាស់ៗអត់ឲ្យលើក ខ្ញុំធ្វើបុណ្យម៉ាសារទៅ ។ ទៅសារក្រោយខ្ញុំទៅលើកម៉ាសារទៀត លើកហើយទៅធ្វើបុណ្យម៉ាសារទៀត ។ ក្រោយ មកបានយូរខ្ញុំអត់បានទៅទេ នេះឲ្យកូនទៅទើបមកម្សិលមិញ ។

ដានី : ពូអត់ចង់ទៅនៅស្រុកកំណើតវិញទេ?

សុន : អត់ចង់ទៅនៅស្រុកខ្ញុំ នៅពិបាករកស៊ី ។

ដានី : ពិបាករកស៊ី?

សុន : បាទ! ដូចថាយើងនោះ មានដីងគ្មានរបរអីនេះ ពិបាកដីរវល់ទឹកលិច ។

ប្រពន្ធ : ធ្វើតែស្រែម៉ាមុខ ។

ដានី : ធ្វើតែស្រែ?

សុន : ធ្វើតែស្រែបានម៉ារស់ៗ រកលុយរកកាក់គ្មាន ខ្ជិលធ្លាប់ដើរច្រើនកន្លែងទៅ វារកស៊ីមិន ដូចមិនហួសស្រុកនេះ ។

ដានី : ហួសស្រុកនេះ?

សុន : យើងនេះយើងធ្វើអីបាន លក់ចេញស្រួល ។ នៅស្រុកខ្ញុំយ៉ាប់លក់ ឥឡូវសូម្បីតែថ្នាំក៏គេ ដាំលែងកើត ។

ដានី : ចុះយើងដាំរហូត រាប់សិបឆ្នាំទៅហើយ ដាំដដែលៗ?

សុន : បាទ! ដូចថាទឹកវា មុនគេថាដីល្បាប់ដីអីហូរចាក់ល្អ អានេះអត់ទេ យូរៗទៅដាំលែងកើត ដដែល ។

ដានី : ចុះពូចឹងបងប្អូនពូសព្វថ្ងៃ គាត់មកនៅជាមួយ?

សុន : ហើយក្មេងៗ២នាក់ ។

ដានី : ពូដូចជាសម័យយើងមុនសមាហរណកម្ម ហើយក្រោយមក ក្រោយសមាហរណកម្ម ពូ ឃើញថាខុសគ្នាយ៉ាងម៉េចដែរ?

សុន : វា.........ប្លែកជាងមុន ។

ដានី : មានការអភិវឌ្ឍន៍?

សុន ៖ បើយើងនិយាយទៅប្រែប្រួលណា យើងមុនដូចថាយើងមកនៅក្រោមដើមឫស្សី យើងមកនៅគ្មានស្អីទេ ដំបូងនឹង សូម្បីតែកង់នឹងក៏មិនចង់មានដែរ ។ ក្រោយមកមានកង់ មានម៉ូតូ ឥឡូវវាកាន់វិវត្តន៍ ។ អានឹងដោយសារអី ដោយសារយើងនៅដូចថាកន្លែងស្រួលរកស៊ីវាមានច្រកចេញចូលអីចឹង ។ យើងធ្វើអាជីវកម្ម យើងធ្វើស្រែ យើងលក់ស្រួល ។ កន្លែងនេះ ធ្វើអីក៏មិនពិបាកទេ លក់ចេញ ។

ដានី ៖ ចឹងពូគិតថាវាស្រួលជាង ហើយយើងសមាហរណកម្មហើយស្រួលជាងមិនទាន់សមាហរណកម្ម?

សុន ៖ បាទ! ម៉ាសារនោះគ្មានសិទ្ធិអីរកអីនឹងបាន យើងរកស៊ីបានមែន តែត្រង់ថាក្នុងលក្ខណៈមួយ វាមិនដូចឥឡូវទេ ។ រកស៊ីក្នុងលក្ខណៈមួយថា គេហាមឃាត់ណា របរអីគេឲ្យរកៗ គេមិនឲ្យរកអត់ ។ បើឥឡូវលើកលែងតែរបរខុសច្បាប់ បើយើងរបរស្របច្បាប់យើងរកបានតាមចិត្ត យើងលក់យើងដូរ មានទីផ្សារ ។ បាទ! និយាយទៅទីផ្សារសេរី ចង់លក់ឲ្យអ្នកណា ចង់លក់នៅកន្លែងណាក៏បាន ។

ដានី ៖ គិតថាឥឡូវយើងរស់នៅស្រួលជាងកាលពីមុន?

សុន ៖ បាទ!

ដានី ៖ បាទ! ហើយសំនួរចុងក្រោយមួយទៀត ដែលឥឡូវនឹងដោយសារមានតុលាការ គេខាងរាជរដ្ឋាភិបាល អង្គការសហប្រជាជាតិគេបង្កើតតុលាការដើម្បីជំនុំជម្រះទោសខ្មែរក្រហម បើតាមយោលបល់ពូផ្ទាល់វិញ ពូយល់ឃើញយ៉ាងម៉េចដែរ ចំពោះការគេបង្កើតតុលាការនឹង ។ ហើយដល់សព្វថ្ងៃនេះ គេជំនុំជម្រះ ដូចថាឌុច កាំងហ្កេកអ៊ាវ ហៅឌុច គាត់ជាអតីតប្រធានមន្ទីរសន្តិសុខស-២១ហៅគុកទួលស្លែង ។ បាទ! អានឹងគេជំនុំជម្រះគាត់រួចហើយៗក្រោយមកទៀត គេនឹងចាប់ផ្ដើមជំនុំជម្រះទោសមេដឹកនាំធំៗដូចថា នួន ជា, អៀង សារី, ប្រពន្ធរបស់គាត់, ខៀវ សំផនអី ។ បើតាមចិត្តរបស់ពូផ្ទាល់ តាមពូយល់ដឹងវិញ យ៉ាងម៉េចដែរ វាតុលាការដែលគេបង្កើតនឹងវាត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវ?

សុន ៖ អានឹងបើតាមខ្ញុំយល់ យើងឥឡូវសង្គមវាមានច្បាប់ទម្លាប់ ចឹងគេរៀបច្បាប់កាត់ទោសកាត់អីនឹង អានឹងជាទស្សនៈខ្ញុំគ្មាននេះស្អីទេ ។ អានឹងវាត្រឹមត្រូវតាមច្បាប់របស់គេហើយអានឹង បើគេរកឃើញកំហុសប្រព្រឹត្តម៉េចវាទៅតាមច្បាប់របស់គេ ។ ម្យ៉ាងៗដូចថាគេរៀបចំចឹង ដើម្បីឲ្យដូចថាមានអ្នករងគ្រោះ ស្ងប់អារម្មណ៍ ស្ងប់ចិត្តណា ព្រោះរបបដែល

យើងឆ្លងកាត់មក ។ អានីងទស្សនៈខ្ញុំ គឺថាយល់ចឹង គឺថាត្រឹមត្រូវ បើយើងតុលាការរៀបចំកាត់ទោសកាត់អីនឹង ។

ដានី ៖ បាទ! ខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំពូទៀតហើយ ចឹងពូមានអីចង់បន្ថែមនូវអ៊ីដែរ?

សុន ៖ អត់ទេ អត់មានអី ។

ដានី ៖ អត់ទេ បាទ!ចឹងខ្ញុំអរគុណពូច្រើនដែលចំណាយពេលឲ្យពួកខ្ញុំសាកសួរពីជីវិត ប្រវត្តិរបស់ពូ ។ បាទ! ខ្ញុំអរគុណពូច្រើន ។

«ចប់»